# បរមត្ថធម៌ ៤



 រៀបរៀងដោយ ព្រះភិក្ខុ កោសល្លធម្ម នួន សារ៉េត (ព្រះជន្ម ៣៥)ថ្ងៃចន្ទ ៩រោច ខែកត្តិក ឆ្នាំវក អដ្ឋស័ក ព.ស.២៥៦០, គ.ស.២០១៦

# បរមត្ថធម៌ ៤ យ៉ាង

(ចិត្ត៨៩ ឬ ១២១ ដួង, ចេតសិក ៥២, រូប ២៨, និព្វាន ២ ឬ ៩ បទ)

❁ចិត្តបរមត្ថ ៨៩ ឬ ១២១ ដួង:

**-កាមាវចរភូមិ ៥៤ ដួង**

**-រូបាវចរភូមិមាន ១៥ ដួង**

**-អរូបាវចរភូមិមាន ១២ ដួង**

**-លោកុត្តរភូមិមាន ៨ ឬ ៤0 ដួង**

**កាមាវចរភូមិមាន ៥៤ ដួង គឺ:**

ក.អកុសលចិត្ត ១២ ដួង

**លោភមូលចិត្ត ៨ ដួង**

**១- សោមនស្សសហគតំ ទិដ្ឋិគតសម្បយុត្តំ អសង្ខារិកំ** លោភមូលចិត្ត កើតរួមជាមួយនឹង សោមនស្សវេទនា ប្រកបដោយទិដ្ឋិ មិនមានអ្នកដទៃបបួលដឹកនាំ ។

**២-សោមនស្សសហគតំ ទិដ្ឋិគតសម្បយុត្តំ សសង្ខារិកំ** លោភមូលចិត្ត កើតរួមជាមួយនឹង សោមនស្សវេទនា ប្រកបដោយទិដ្ឋិ មានអ្នកដទៃបបួលដឹកនាំ ។

**៣- សោមនស្សសហគតំ ទិដ្ឋិគតវិប្បយុត្តំ អសង្ខារិកំ** លោភមូលចិត្ត កើតរួមជាមួយនឹង សោមនស្សវេទនា ប្រាសចាកទិដ្ឋិ មិនមានអ្នកដទៃបបួលដឹកនាំ ។

**៤- សោមនស្សសហគតំ ទិដ្ឋិគតវិប្បយុត្តំ សសង្ខារិកំ** លោភមូលចិត្ត កើតរួមជាមួយ នឹង សោមនស្សវេទនា ប្រាសចាកទិដ្ឋិ មានអ្នកដទៃបបួលដឹកនាំ ។

**៥- ឧបេក្ខាសហគតំ ទិដ្ឋិគតសម្បយុត្តំ អសង្ខារិកំ** លោភមូលចិត្ត កើតរួមជាមួយនឹង ឧបេក្ខាវេទនា ប្រកបដោយទិដ្ឋិ មិនមានអ្នកដទៃបបួលដឹកនាំ ។

**៦- ឧបេក្ខាសហគតំ ទិដ្ឋិគតសម្បយុត្តំ សសង្ខារិកំ** លោភមូលចិត្ត កើតរួមជាមួយនឹង ឧបេក្ខាវេទនា ប្រកបដោយទិដ្ឋិ មានអ្នកដទៃបបួលដឹកនាំ ។

**៧- ឧបេក្ខាសហគតំ ទិដ្ឋិគតវិប្បយុត្តំ អសង្ខារិកំ** លោភមូលចិត្ត កើតរួមជាមួយនឹង ឧបេក្ខាវេទនា ប្រាសចាកទិដ្ឋិ មិនមានអ្នកដទៃបបួលដឹកនាំ ។

**៨- ឧបេក្ខាសហគតំ ទិដ្ឋិគតវិប្បយុត្តំ សសង្ខារិកំ** លោភមូលចិត្ត កើតរួមជាមួយនឹង ឧបេក្ខាវេទនា ប្រាសចាកទិដ្ឋិ មានអ្នកដទៃបបួលដឹកនាំ ។

## ទោសមូលចិត្ត ២ ដួង

**១- ទោមនស្សសហគតំ បដិឃសម្បយុត្តំ អសង្ខារិកំ** ទោសមូលចិត្ត កើតរួមជាមួយនឹង ទោមនស្សវេទនា ប្រកបដោយសេចក្ដីថ្នាំងថ្នាក់ចិត្ត មិនមានអ្នកដទៃបបួលដឹកនាំ ។

**២- ទោមនស្សសហគតំ បដិឃសម្បយុត្តំ សសង្ខារិកំ** ទោសមូលចិត្ត កើតរួមជាមួយនឹង ទោមនស្សវេទនា ប្រកបដោយសេចក្ដីថ្នាំងថ្នាក់ចិត្ត មានអ្នកដទៃបបួលដឹកនាំ ។

## មោហមូលចិត្ត ២ ដួង

**១- ឧបេក្ខាសហគតំ វិចិកិច្ឆាសម្បយុត្តំ** មោហមូលចិត្ត កើតរួមជាមួយនឹង ឧបេក្ខាវេទនា ប្រកបដោយ វិចិកិច្ឆា (សេចក្ដីសង្ស័យ) ។

**២- ឧបេក្ខាសហគតំ ឧទ្ធច្ចសម្បយុត្តំ** មោហមូលចិត្ត កើតរួមជាមួយនឹង ឧបេក្ខាវេទនា ប្រកបដោយ ឧទ្ធច្ចៈ (សេចក្តីរាយមាយចិត្ត) ។

សេចក្តីតទៅនេះ នឹងសង្គ្រោះកម្មបថ ១០ ចូលក្នុងអកុសលចិត្ត ១២ តទៅៈ

## មោហ (ការមិនដឹង) ក្នុងធម៌ ៨ យ៉ាង

**១.ទុក្ខេ អញ្ញាណំ** សេចក្តីមិនដឹង ក្នុងទុក្ខសច្ច ។

**២.ទុក្ខសមុទយេ អញ្ញាណំ** សេចក្តីមិនដឹង ក្នុងទុក្ខសមុទយសច្ច ។

**៣.ទុក្ខនិរោធេ អញ្ញាណំ** សេចក្តីមិនដឹង ក្នុងទុក្ខនិរោធសច្ច ។

**៤.ទុក្ខនិរោធគាមិនីបដិបទាយ អញ្ញាណំ** សេចក្តីមិនដឹង ក្នុងមគ្គសច្ច ដែលជាផ្លូវនាំឲ្យដល់ទីរំលត់ទុក្ខ ១២ កង ។

**៥.បុព្វន្តេ អញ្ញាណំ** សេចក្តីមិនដឹង ក្នុងខន្ធ ធាតុ អាយតន ជាដើម ។

**៦.អបរន្តេ អញ្ញាណំ** សេចក្តីមិនដឹង ក្នុងខន្ធ ធាតុ អាយតន ដែលជាអនាគត ។

**៧.បុព្វន្តាបរន្តេ អញ្ញាណំ** សេចក្តីមិនដឹង ក្នុងខន្ធ ធាតុ អាយតន ដែលជាអតីត និង អនាគត ។

**៨.ឥទប្បច្ចយតា បដិច្ចសមុប្បន្នេសុ ធម្មេសុ អញ្ញាណំ** សេចក្តីមិនដឹង ក្នុងបដិច្ចសមុប្បាទ គឺ មិនដឹងក្នុងធម៌ទាំងឡាយ ដែលអាស្រ័យគ្នា កើតឡើងថា ធម៌នេះជាបច្ច័យ ។

## សេចក្តីសង្ស័យ ៨ យ៉ាង

**១.ពុទ្ធេ កង្ខតិ** សង្ស័យក្នុងព្រះពុទ្ធ ។

**២.ធម្មេ កង្ខតិ** សង្ស័យក្នុងព្រះធម៌ ។

**៣.សង្ឃេ កង្ខតិ** សង្ស័យក្នុងព្រះសង្ឃ ។

**៤.សិក្ខាយ កង្ខតិ** សង្ស័យក្នុងសិក្ខា (ត្រៃសិក្ខា) ។

**៥.បុព្វន្តេ កង្ខតិ** សង្ស័យក្នុង ខន្ធ ធាតុ អាយតន ដែលជាអតីត ។

**៦.អបរន្តេ កង្ខតិ** សង្ស័យក្នុងខន្ធ ធាតុ អាយតន ដែលជាអនាគត ។

**៧.បុព្វន្តាបរន្តេ កង្ខតិ** សង្ស័យក្នុងខន្ធ ធាតុ អាយតន ដែលជាអតីត និង អនាគត ។

**៨.បដិច្ចសមុប្បាទេ កង្ខតិ** សង្ស័យក្នុងបដិច្ចសមុប្បាទធម៌ ។

## នីវរណធម៌ ៥ មានធម៌លៈដូច្នេះ

**១.កាមឆន្ទ** លះបង់ចេញដោយធម៌ ៣ គឺៈ

-ដោយតទង្គនិស្សរណ គឺ វិបស្សនា ។

-ដោយវិក្ខម្ភននិស្សរណ គឺ អសុភឈាន ។

-ដោយសមុច្ឆេទនិស្សរណ គឺ អរហត្តមគ្គ ។

**២.ព្យាបាទ** លះចេញដោយធម៌ ២ គឺៈ

-ដោយវិក្ខម្ភននិស្សរណ គឺ មេត្តាឈាន ។

-ដោយសមុច្ឆេទនិស្សរណ គឺ អនាគាមិមគ្គ ។

**៣.ថីនមិទ្ធ** លះចេញដោយធម៌ ២ គឺៈ

-ដោយវិក្ខម្ភននិស្សរណ គឺអលោកសញ្ញា ។

-ដោយសមុច្ឆេទនិស្សរណ គឺ អរហត្តមគ្គ ។

**៤.ឧទ្ធច្ចកុក្កុច្ច** លះចេញដោយវិក្ខម្ភននិស្សរណ ដោយសមថកម្មដ្ឋាន យ៉ាងណាមួយ ។

-កុក្កុច្ច លះចេញដោយសមុច្ឆេទនិស្សរណ គឺ ដោយអនាគាមិមគ្គ ។

-ឧទ្ធច្ច លះចេញដោយសមុច្ឆេទនិស្សរណ គឺ ដោយអរហត្តមគ្គ ។

**៥.វិចិកិច្ឆា** លះចេញដោយធម៌ ២ គឺៈ

-ដោយវិក្ខម្ភននិស្សរណ គឺ ឈានយ៉ាងណាមួយ ។

-ដោយសមុច្ឆេទនិស្សរណ គឺ បឋមមគ្គ ។

## អកុសលកម្មបថ ១០

ក.កាយកម្ម ៣ គឺៈ

**១.បាណាតិបាតា** ការសម្លាប់សត្វ ។

**២.អទិន្នាទានា** ការលួចទ្រព្យអ្នកដទៃ ។

**៣.កាមេសុមិច្ឆាចារា** ការប្រព្រឹត្តខុសក្នុងកាម ។

**ខ.វចីកម្ម ៤ គឺៈ**

**១.មុសាវាទោ** ការនិយាយពាក្យកុហក ។

**២.បិសុណាវាទោ** ការនិយាយពាក្យញុះញង់ ។

**៣.ផរុសវាទោ** ការនិយាយពាក្យគ្រោតគ្រាត ។

**៤.សម្ផប្បលាបោ** ការនិយាយពាក្យឥតប្រយោជន៍ ។

**គ.មនោកម្ម ៣ គឺៈ**

**១.អភិជ្ឈា** ការសំឡឹងរំពៃ ចង់បានទ្រព្យគេ ។

**២.ព្យាបាទោ** ការចងគំនុំព្យាបាទ ។

**៣.មិច្ឆាទិដ្ឋិ** ការយល់ខុស (គឺនិយតមិច្ឆាទិដ្ឋិ) ។

## ប្ចាណាតិបាត មានអង្គ ៥

**១.បាណោ** សត្វមានជីវិត ។

**២.បាណសញ្ញិតា** សេចក្តីដឹងថា សត្វមានជីវិត ។

**៣.វធកចិត្តំ** ចិត្តគិតនឹងសម្លាប់ ។

**៤.ឧបក្កមោ** ព្យាយាមនឹងសម្លាប់ ។

**៥.តេន មរណំ** សត្វស្លាប់ដោយព្យាយាមនោះ ។

## អទិន្នាទាន មានអង្គ ៥

**១.បរបរិគ្គហិតំ** ទ្រព្យដែលមានម្ចាស់គេហួងហែងរក្សា ។

**២.បរបរិគ្គហិតសញ្ញិតា** សេចក្តីដឹងថា ទ្រព្យមានម្ចាស់គេហួងហែងរក្សា ។

**៣.ថេយ្យចិត្តំ** ចិត្តគិតនឹងលួច ។

**៤.ឧបក្កមោ** ព្យាយាមនឹងលួច ។

**៥.តេន ហរណំ** លួចបានដោយព្យាយាមនោះ ។

## កាមេសុមិច្ឆាចារ មានអង្គ ៤

**១.អគមនីយដ្ឋានំ** ស្ត្រីដែលមិនគួរនឹងគប់រក គឺ ស្ត្រីដែលមានគេហួងហែងរក្សា ។

| | |
|---|---|
| **២.តស្ស សេវនចិត្តំ** | ចិត្តគិតនឹងសេពនូវមេថុនធម្ម ក្នុងស្ត្រីនោះ ។ |
| **៣.ឧបក្កមោ** | ព្យាយាមនឹងសេពនូវមេថុនធម្មនោះ ។ |
| **៤.មគ្គេន មគ្គប្បដិបាទនំ** | ញុំាងមគ្គនិងមគ្គឲ្យដល់គ្នា ។ |

### មុសាវាទ មានអង្គ ៤

| | |
|---|---|
| **១.អតថំ វត្ថុ** | វត្ថុមិនពិត ។ |
| **២.វិសំវាទនចិត្តំ** | ចិត្តគិតនឹងពោលឲ្យខុស ។ |
| **៣.តជ្ជោ វាយាមោ** | ព្យាយាមនឹងពោលឲ្យខុស ។ |
| **៤.បរស្ស តទត្ថវិជាននំ** | ញុំាងអ្នកដទៃ ឲ្យដឹងច្បាស់នូវសេចក្តីនោះ ។ |

### សុរាមេរយ មានអង្គ ៤

| | |
|---|---|
| **១.មជ្ជនីយវត្ថុ** | វត្ថុជាទីតាំងនៃសេចក្តីស្រវឹង គឺ សុរា និង មេរ័យ ។ |
| **២.បាតុកម្យតាចិត្តំ** | ចិត្តគិតបំរុងនឹងផឹក ។ |
| **៣.តជ្ជោ វាយាមោ** | ព្យាយាមនឹងផឹកទឹកស្រវឹងនោះ ។ |
| **៤.តស្សបានំ** | បានផឹកនូវទឹកស្រវឹងនោះ ឲ្យកន្លងបំពង់កចូលទៅ ។ |

### អព្រហ្មចរិយ មានអង្គ ៤

| | |
|---|---|
| **១.សេវនចិត្តំ** | ចិត្តគិតនឹងសេព ។ |
| **២.តេទនវត្ថុ** | វត្ថុជាទីទម្លាយនូវសីល គឺ ទ្វារទាំង ៣០ ទ្វារណាមួយ ។ |

**៣.តជ្ជោ វាយាមោ** ព្យាយាមនឹងសេពនូវមេថុនធម្មនោះ ។

**៤.មគ្គេន មគ្គប្បដិបាទនំ** ញុំាងមគ្គឲ្យដល់គ្នា ។

## វិកាលភោជន មានអង្គ ៣

**១.វិកាលោ** កាលខុស គឺ ព្រះអាទិត្យជ្រេទៅហើយ ដរាបទល់នឹងអរុណរះ ។

**២.យាវកាលិកំ** របស់ដែលគួរបរិភោគបានក្នុងកាល គឺតាំងពីអរុណរះឡើងដរាបដល់ថ្ងៃត្រង់។

**៣.អជ្ឈោហរណំ** បានលេបចូលទៅក្នុងបំពង់ក ។

## នច្ចគីត និង មាលារួមគ្នាបានជាសិក្ខាបទមួយ មានអង្គ ៦

**១.នច្ចគីតាទិ** ការល្បែងមានរាំ និងច្រៀងជាដើម ។

**២.ភគ្គកម្យតាចិត្តំ** ចិត្តគិតបំរុងនឹងធ្វើ ។

**៣.សុតទស្សនត្ថាយគមនំ** ទៅដើម្បីនឹងស្តាប់ឬមើល ហើយបានស្តាប់ឬមើល ។

**៤.មាលាទិ** វត្ថុសម្រាប់ប្រដាប់កាយ មានផ្កាកម្រងជាដើម ។

**៥.ធារណាច្ឆន្ទតា** សេចក្តីប្រាថ្នា នឹងប្រដាប់តាក់តែង ។

**៦.តស្ស ធារណំ** បានប្រដាប់តាក់តែង នូវវត្ថុសម្រាប់ប្រដាប់កាយ មានផ្កាកម្រងជាដើមនោះ ។

## ឧច្ចាសយន មានអង្គ ៣

**១.ឧច្ចាសយនមហាសយនំ** ទីដេកទីអង្គុយ ដ៏ខ្ពស់ហួសប្រមាណ ។

**២.បរិភោគចិត្តំ** ចិត្តគិតនឹងដេក ឬអង្គុយ ។

**៣.បរិភោគករណំ** បានដេក ឬអង្គុយ ។

## ជាតរូប មានអង្គ ៣

**១.ជាតរូបរជតំ** មាសឬប្រាក់ ជាអកប្បិយភណ្ឌ ។

**២.អត្តុទ្ទិសតា** ចំពោះជារបស់ខ្លួន ។

**៣.បដិគ្គណ្ហាតិ** បានទទួលកាន់យកដោយខ្លួនឯង ឬប្រើអ្នកដទៃឲ្យទទួលកាន់យក ហើយត្រេកអរចំពោះមាស និង ប្រាក់នោះ ។

## បិសុណាវាចា មានអង្គ ៤

**១.ភិន្ទិតព្វោ បរោ** អ្នកដទៃមានរូប គឺ ខ្លួនគប្បីញុះញង់បំបែក ។

**២.ភេទនបុរេក្ខារតា** គិតនឹងញុះញង់បំបែកអ្នកដទៃនោះ ។

**៣.តជ្ជោ វាយាមោ** ព្យាយាមនឹងញុះញង់បំបែកបំបាក់អ្នកដទៃនោះ ។

**៤.តស្ស តទត្ថវិជាននំ** ញុំាងអ្នកដទៃ ឲ្យដឹងច្បាស់នូវដំណើរដែលខ្លួនញុះញង់បំបែកបំបាក់នោះ។

## ផរុសវាចា មានអង្គ ៣

**១.អក្កោសិតព្វោ បរោ** អ្នកដទៃដែលមានរូប គឺ ខ្លួនគប្បីជេរប្រទេច ។

**២.កុប្បិតចិត្តំ** ចិត្តខឹងរន្ធត់ ។

**៣.អក្កោសនា** បានជេរប្រទេចគេ ។

## សម្ផប្បលាប មានអង្គ ២

**១.ភារតយុទ្ធសិតាហរណាទិនិរត្ថកថា** ពាក្យឥតប្រយោជន៍ មានរឿងចំបាំងនៃមហារត: និងរឿងយក្សលួចនាំនាងសិតាយកទៅជាដើម ។

**២.តថារូបីកថាកថនំ** ពោលនូវពាក្យឥតប្រយោជន៍ មានសភាពដូច្នេះ ។

## អភិជ្ឈា មានអង្គ ២

**១.បរភណ្ឌំ** ទ្រព្យជារបស់អ្នកដទៃ ។

**២.អត្តនោ បរិណាមនំ** គិតចង់បង្អោនទ្រព្យរបស់អ្នកដទៃនោះ ឲ្យបានមកជាទ្រព្យរបស់ខ្លួន ដោយកលឧបាយផ្សេងៗ ។

## ព្យាបាទ មានអង្គ ២

**១.បរសត្តោ** អ្នកដទៃក្រៅពីខ្លួន ។

**២.តស្ស តំ តំ វិនាសចិន្តា** គិតគុំកួនប្រុងនឹងឲ្យអ្នកដទៃនោះ ដល់នូវសេចក្ដីវិនាសដោយហេតុនោះៗ ។

## មិច្ឆាទិដ្ឋិ មានអង្គ ២

**១.វត្ថុនោ ច គហិតាការវិបរិតតា** ចិត្តប្រែប្រួលដោយអាការខុសអំពីព្រះរតនត្រ័យជាដើម។

**២.យថា ច នំ គណ្ហាតិ តថាភាវេន តស្សូបដ្ឋានំ** គំនិតដែលយល់ខុសនោះ ឃើញខុសយ៉ាងណា ក៏ប្រកាន់ខុសនោះថាជាត្រូវវិញ ។

## កិលេស ១៥០០

អារម្មណ៍ដែលជាហេតុ ឲ្យកិលេសកើត មាន ១៥០ គឺ ចេតសិក ៥២, និប្ផន្នរូប ១៨ និង លក្ខណរូប ៤ រួមជា ៧៥ ។ អារម្មណ៍ ៧៥ នេះ កើតក្នុងសន្តាន ២ គឺ អជ្ឈត្តសន្តាន និង ពហិទ្ធ-សន្តាន រួមជាអារម្មណ៍ ១៥០ ។ ហើយគុណនឹង កិលេស ១០ ត្រូវជាកិលេស ១៥០០ ។

## **តណ្ហា ១០៨**

តណ្ហាក្នុងអាយតនៈ ១២ បូកនឹង តណ្ហា ៣ គឺ កាមតណ្ហា, ភវតណ្ហា, និង វិភវតណ្ហា ត្រូវជា ៣៦ ។ បូកក្នុងកាលទាំង ៣ គឺ អតីតកាល មាន ៣៦, បច្ចុប្បន្នកាល មាន ៣៦, អនាគតកាល មាន ៣៦ ត្រូវជា តណ្ហាទាំងអស់ មាន ១០៨ ។

## **ឧបកលេស ១៦**

| | |
|---|---|
| **១.អភិជ្ឈាវិសមលោភ** | ការប្រាថ្នាចង់បាន ។ |
| **២.ទោស** | ការប្រទូសនឹងអារម្មណ៍ ។ |
| **៣.កោធ** | ការខឹងក្រោធ ។ |
| **៤.ឧបនាហ** | ចងក្រោធទុក ។ |
| **៥.មក្ខ** | រមិលគុណ ។ |
| **៦.បលាស** | វាយឫកស្មើ លើកខ្លួនស្មើគេ ។ |
| **៧.ឥស្សា** | ការច្រណែន ។ |
| **៨.មច្ឆរិយ** | ការកំណាញ់ ។ |
| **៩.មាយា** | ការលាក់ពុត ។ |
| **១០.សាថេយ្យ** | ការអំនួត ។ |
| **១១.ថម្ភ** | រឹងថ្លឹង ។ |
| **១២.សារម្ភ** | ប្រណាំងវាសនា ។ |

**១៣.មាន** ការលើកដម្កើងខ្លួន ។

**១៤.អតិមាន** ការមើលងាយគេ ។

**១៥.មទ** ការស្រវឹង ។

**១៦.បមាទ** ការប្រមាទ ។

**សំយោជន ១០**

**កាមរាគ, បដិឃ, មាន, ទិដ្ឋិ, វិចិកិច្ឆា, សីលព្វតបរាមាស, ភវរាគ, ឥស្សា, មច្ឆរិយ, អវិជ្ជា ។**

**កលេស ១០**

**លោភ, ទោស, មោហ, មាន, ទិដ្ឋិ, វិចិកិច្ឆា, ថីន, ឧទ្ធច្ច, អហិរិក, អនោត្តប្ប ។**

១- អហេតុកចិត្ត ១៨ ដួង:

**អហេតុកអកុសលវិបាកចិត្ត ៧ ដួង**

**១- ឧបេក្ខាសហគតំ ចក្ខុវិញ្ញាណំ អកុសលវិបាកចិត្តំ** អកុសលវិបាកចិត្ត កើតរួមជាមួយនឹង ឧបេក្ខាវេទនា ឃើញរូបមិនល្អ ។

**២- ឧបេក្ខាសហគតំ សោតវិញ្ញាណំ អកុសលវិបាកចិត្តំ** អកុសលវិបាកចិត្ត កើតរួមជាមួយនឹង ឧបេក្ខាវេទនា ឮសម្លេងមិនល្អ ។

**៣- ឧបេក្ខាសហគតំ ឃានវិញ្ញាណំ អកុសលវិបាកចិត្តំ** អកុសលវិបាកចិត្ត កើតរួមជាមួយនឹង ឧបេក្ខាវេទនា ធំក្លិនមិនល្អ ។

**៤- ឧបេក្ខាសហគតំ ជិវ្ហាវិញ្ញាណំ អកុសលវិបាកចិត្តំ** អកុសលវិបាកចិត្ត កើតរួមជា

មួយនឹង ឧបេក្ខាវេទនា ដឹងរសមិនល្អ ។

**៥- ទុក្ខសហគតំ កាយវិញ្ញាណំ អកុសលវិបាកចិត្តំ** អកុសលវិបាកចិត្ត កើតរួមជាមួយនឹង ទុក្ខវេទនា ប៉ះផ្ទប់នូវកាយមិនជាទីប្រាថ្នា ។

**៦- ឧបេក្ខាសហគតំ មនោធាតុ អកុសលវិបាកចិត្តំ** អកុសលវិបាកចិត្ត កើតរួមជាមួយនឹង ឧបេក្ខាវេទនា ទទួលនូវអារម្មណ៍មិនល្អ ។

**៧- ឧបេក្ខាសហគតំ មនោវិញ្ញាណធាតុ អកុសលវិបាកចិត្តំ** អកុសលវិបាកចិត្ត កើតរួមជាមួយនឹង ឧបេក្ខាវេទនា ពិចារណានូវអារម្មណ៍មិនល្អ ។

## អហេតុកកុសលវិបាកចិត្ត ៨ ដួង

**១- ឧបេក្ខាសហគតំ ចក្ខុវិញ្ញាណំ កុសលវិបាកចិត្តំ** កុសលវិបាកចិត្ត កើតរួមជាមួយនឹង ឧបេក្ខាវេទនា ឃើញរូបល្អ ។

**២- ឧបេក្ខាសហគតំ សោតវិញ្ញាណំ កុសលវិបាកចិត្តំ** កុសលវិបាកចិត្តកើតរួមជាមួយនឹង ឧបេក្ខាវេទនា ឮសម្លេងល្អ ។

**៣- ឧបេក្ខាសហគតំ ឃានវិញ្ញាណំ កុសលវិបាកចិត្តំ** កុសលវិបាកចិត្តកើតរួមជាមួយនឹង ឧបេក្ខាវេទនា ធំក្លិនល្អ ។

**៤-ឧបេក្ខាសហគតំ ជិវ្ហាវិញ្ញាណំ កុសលវិបាកចិត្តំ** កុសលវិបាកចិត្ត កើតរួមជាមួយនឹង ឧបេក្ខាវេទនា ស្រូបរសល្អ ។

**៥-សុខសហគតំ កាយវិញ្ញាណំ កុសលវិបាកចិត្តំ** កុសលវិបាកចិត្ត កើតរួមជាមួយនឹង សុខវេទនា ប៉ះខ្ទប់សម្ផស្សល្អ ។

**៦-ឧបេក្ខាសហគតំ មនោធាតុ កុសលវិបាកចិត្តំ** កុសលវិបាកចិត្ត កើតរួមជាមួយនឹង ឧបេក្ខាវេទនា ទទួលនូវបញ្ចារម្មណ៍ល្អ ។

**៧-សោមនស្សសហគតំ មនោវិញ្ញាណធាតុ អហេតុកកុសលវិបាកចិត្តំ** អហេតុក-កុសលវិបាកចិត្ត កើតរួមជាមួយនឹង សោមនស្សវេទនា ពិចារណានូវបញ្ចារម្មណ៍ល្អ ។

**៨-ឧបេក្ខាសហគតំ មនោវិញ្ញាណធាតុ អហេតុកកុសលវិបាកចិត្តំ** អហេតុកកុសល-វិបាកចិត្ត កើតរួមជាមួយនឹង ឧបេក្ខាវេទនា ពិចារណានូវបញ្ចារម្មណ៍ល្អ ។

## អហេតុកកិរិយាចិត្ត ៣ ដួង

**១-ឧបេក្ខាសហគតំ មនោធាតុ អហេតុកកិរិយាចិត្តំ** អហេតុកកិរិយាចិត្ត កើតរួមជាមួយនឹង ឧបេក្ខាវេទនា រាវរកអារម្មណ៍តាមបញ្ចទ្វារ ។

**២-ឧបេក្ខាសហគតំ មនោវិញ្ញាណធាតុ អហេតុកកិរិយាចិត្តំ** អហេតុកកិរិយាចិត្ត កើតរួមជាមួយនឹង ឧបេក្ខាវេទនា រាវរកអារម្មណ៍តាមមនោទ្វារ ។

**៣-សោមនស្សសហគតំ មនោវិញ្ញាណធាតុ អហេតុកកិរិយាចិត្តំ** អហេតុកកិរិយាចិត្ត កើតរួមជាមួយនឹង សោមនស្សវេទនា គឺការញញឹមរបស់ព្រះអរហន្ត ។

## កិច្ច ១៤ របស់អហេតុកចិត្ត ១៨

**១.ចក្ខុវិញ្ញាណ ២** ធ្វើទស្សនកិច្ច (កិច្ចឃើញរូប) ។

**២.សោតវិញ្ញាណ ២** ធ្វើសវនកិច្ច (កិច្ចឮសំឡេង) ។

**៣.ឃានវិញ្ញាណ ២** ធ្វើឃាយនកិច្ច (កិច្ចធំក្លិន) ។

**៤.ជិវ្ហាវិញ្ញាណ ២** ធ្វើសាយនកិច្ច (កិច្ចស្រូបរស) ។

**៥.កាយវិញ្ញាណ ២** ធ្វើផុស្សនកិច្ច (កិច្ចប៉ះខ្ទប់សម្ផស្ស) ។

**៦.សម្បដិច្ឆន្នចិត្ត ២** ធ្វើសម្បដិច្ឆន្នកិច្ច (កិច្ចទទួលបញ្ចារម្មណ៍) ។

**៧.ឧបេក្ខាសន្តីរណចិត្ត ២ ធ្វើកិច្ច ៥ គឺៈ**

-**បដិសន្ធិកិច្ច** ធ្វើការបន្តក្នុងភពថ្មី

-**ភវង្គកិច្ច** ធ្វើការរក្សាភព

-**ចុតិកិច្ច** ធ្វើការឃ្លាតចាកភព

-**សន្តីរណកិច្ច** ធ្វើការពិចារណាអារម្មណ៍

-**តទាលម្ពណកិច្ច** ធ្វើការទទួលអារម្មណ៍តពីជវ័ន ។

**៨.សោមនស្សសន្តីរណចិត្ត ១** ធ្វើកិច្ច ២ គឺៈ

-**សន្តីរណកិច្ច** ធ្វើការពិចារណាអារម្មណ៍

-**តទាលម្ពណកិច្ច** ធ្វើការទទួលអារម្មណ៍តពីជវ័ន ។

**៩.បញ្ចទ្វារាវជ្ជនចិត្ត ១** ធ្វើអាវជ្ជនកិច្ច គឺ ការទទួលបញ្ចារម្មណ៍ ។

**១០.មនោទ្វារាវជ្ជនចិត្ត ១ ធ្វើកិច្ច ២ គឺៈ**

-**អាវជ្ជនកិច្ច** គឺ ការទទួលអារម្មណ៍តាមមនោទ្វារ

-**វោដ្ឋព្វនកិច្ច** គឺ ការកំណត់អារម្មណ៍តាមបញ្ចទ្វារ ។

**១១.ហសិតុប្បាទចិត្ត ១** ធ្វើជវនកិច្ច ការសេពសោយអារម្មណ៍ ធ្វើឲ្យកើតការញញឹមរបស់ព្រះអរហន្ត ។

## **១.អតិមហន្តារម្មណ៍ទី ១**

**១.អតីតភវង្គ** បានដល់ កាមបដិសន្ធិ ១០

**២.ភវង្គចលន** បានដល់ កាមបដិសន្ធិ ១០ } ផុតវិថី

**៣.ភវង្គុបច្ឆេទ** បានដល់ កាមបដិសន្ធិ ១០

**៤.បញ្ចទ្វារាវជ្ជន** បានដល់ កិរិយាមនោធាតុ ១

**៥.បញ្ចវិញ្ញាណ** បានដល់ ទ្វិបញ្ចវិញ្ញាណ ១០

**៦.សម្បដិច្ឆន្ន** បានដល់ វិបាកមនោធាតុ ២

**៧.សន្តីរណ** បានដល់ សន្តីរណវិបាក ៣

**៨.វោដ្ឋព្វន** បានដល់ កិរិយាមនោវិញ្ញាណ ១

**៩**, **១០**, **១១**, **១២**, **១៣**, **១៤**, **១៥ ជវ័ន** បានដល់ កាមជវ័ន ២៩ គឺ អកុសលចិត្ត ១២, ហសិតុប្បាទចិត្ត ១, មហាកុសលចិត្ត ៨, មហាកិរិយាចិត្ត ៨ ។

**១៦.តទាលម្ពណ**

**១៧.តទាលម្ពណ** } សន្តីរណវិបាក ៣, មហាវិបាក ៨, ហើយក៏ផុតចាកវិថីចិត្ត ។

## **មហន្តារម្មណ៍ មាន ២ ន័យ**

## **២.មហន្តារម្មណ៍ទី ១**

**១.អតីតភវង្គ** កើត ២ ខណៈ

**៣.ភវង្គចលន** កើត ១ ខណៈ ផុតវិថី

**៤.ភវង្គុបច្ឆេទ** កើត ១ ខណៈ

**៥.បញ្ចទ្វារាវជ្ជន** កើត ១ ខណៈ ជាវិថីទី ១

**៦.បញ្ចវិញ្ញាណ** កើត ១ ខណៈ ជាវិថីទី ២

**៧.សម្បដិច្ឆន្ន** កើត ១ ខណៈ ជាវិថីទី ៣

**៨.សន្តីរណ** កើត ១ ខណៈ ជាវិថីទី ៤

**៩.វោដ្ឋព្វន** កើត ១ ខណៈ ជាវិថីទី ៥

**១០, ១១, ១២, ១៣, ១៤, ១៥, ១៦ ជវន័** គឺ ជវនចិត្ត ៧ ខណៈ ជាវិថីទី ៦

**១៧.ភវង្គ** (ផុតចាកវិថី) ។

## ២.មហន្តារម្មណ៍ទី ២

**១.អតីតភវង្គ** ៣ ខណៈ

**៤.ភវង្គចលន** ១ ខណៈ

**៥.ភវង្គុបច្ឆេទ** ១ ខណៈ

(១–៥) ផុតវិថី

**៦.បញ្ចទ្វារាវជ្ជន** ១ ខណៈ ជាវិថីទី ១

**៧.បញ្ចវិញ្ញាណ** ១ ខណៈ ជាវិថីទី ២

**៨.សម្បដិច្ឆន្ន** ១ ខណៈ ជាវិថីទី ៣

**៩.សន្តីរណ** ១ ខណៈ ជាវិថីទី ៤

**១០.ទោឌ្ឋព្វន** ១ ខណៈ ជាវិថីទី ៥

**១១, ១២, ១៣, ១៤, ១៥, ១៦, ១៧ ជវ័ន** ៧ ខណៈ ជាវិថីទី ៦

**ផុតវិថី ភវង្គបាត** ចិត្តប្រព្រឹត្តទៅក្នុងក្រសែភវង្គ ។

## បរិត្តារម្មណ៍មាន ៦ ន័យ

## ៣.បរិត្តារម្មណ៍ទី ១

**១.អតីតភវង្គ** កើត ៤ ខណៈ
**៥.ភវង្គចលន** កើត ១ ខណៈ
**៦.ភវង្គុបច្ឆេទ** កើត ១ ខណៈ
} ផុតវិថី

**៧.បញ្ចទ្វារាវជ្ជន** កើត ១ ខណៈ ជាវិថីទី ១

**៨.បញ្ចវិញ្ញាណ** កើត ១ ខណៈ ជាវិថីទី ២

**៩.សម្បដិច្ឆន្ន** កើត ១ ខណៈ ជាវិថីទី ៣

**១០.សន្តីរណ** កើត ១ ខណៈ ជាវិថីទី ៤

**១១**, **១២**, **១៣** **ទោឌ្ឋពូន** កើត ៣ ខណៈ ជាវិថីទី ៥

**១៤**, **១៥**, **១៦**, **១៧** **ភវង្គ** កើត ៤ ខណៈ ផុតវិថី ។

## ៣.បរិត្តារម្មណ៍ទី ២

**១.អតីតភវង្គ** កើត ៥ ខណៈ
**៦.ភវង្គចលន** កើត ១ ខណៈ
**៧.ភវង្គុបច្ឆេទ** កើត ១ ខណៈ
} ផុតវិថី

**៨.បញ្ចទ្វារាវជ្ជន** កើត ១ ខណៈ ជាវិថីទី ១

**៩.បញ្ចវិញ្ញាណ** កើត ១ ខណៈ ជាវិថីទី ២

**១០.សម្បដិច្ឆន្ន** កើត ១ ខណៈ ជាវិថីទី ៣

**១១.សន្តីរណ** កើត ១ ខណៈ ជាវិថីទី ៤

**១២**, **១៣**, **១៤** វោដ្ឋពូន កើត ៣ ខណៈ ជាវិថីទី ៥

**១៥**, **១៦**, **១៧** ភវង្គ កើត ៣ ខណៈ ផុតវិថី ។

## ៣.បរិត្តារម្មណ៍ទី ៣

**១.អតីតភវង្គ** កើត ៦ ខណៈ
**៧.ភវង្គចលន** កើត ១ ខណៈ
**៨.ភវង្គុបច្ឆេទ** កើត ១ ខណៈ
} ផុតវិថី

**៩.បញ្ចទ្វារាវជ្ជន** កើត ១ ខណៈ ជាវិថីទី ១

**១០.បញ្ចវិញ្ញាណ** កើត ១ ខណៈ ជាវិថីទី ២

**១១.សម្បដិច្ឆន្ន** កើត ១ ខណៈ ជាវិថីទី ៣

**១២.សន្តីរណ** កើត ១ ខណៈ ជាវិថីទី ៤

**១៣, ១៤, ១៥ វោដ្ឋព្វន** កើត ៣ ខណៈ ជាវិថីទី ៥

**១៦, ១៧ ភវង្គ** កើត ២ ខណៈ ផុតវិថី ។

## ៣.បរិត្តារម្មណ៍ទី ៤

**១.អតីតភវង្គ** កើត ៧ ខណៈ }

**៨.ភវង្គចលន** កើត ១ ខណៈ } ផុតវិថី

**៩.ភវង្គុបច្ឆេទ** កើត ១ ខណៈ }

**១០.បញ្ចទ្វារាវជ្ជន** កើត ១ ខណៈ ជាវិថីទី ១

**១១.បញ្ចវិញ្ញាណ** កើត ១ ខណៈ ជាវិថីទី ២

**១២.សម្បដិច្ឆន្ន** កើត ១ ខណៈ ជាវិថីទី ៣

**១៣.សន្តីរណ** កើត ១ ខណៈ ជាវិថីទី ៤

**១៤, ១៥, ១៦ វោដ្ឋព្វន** កើត ៣ ខណៈ ជាវិថីទី ៥

**១៧.ភវង្គ** កើត ១ ខណៈ ផុតវិថី ។

## ៣.បរិត្តារម្មណ៍ទី ៥

**១.អតីតភវង្គ** កើត ៨ ខណៈ

**៩.ភវង្គចលន** កើត ១ ខណៈ ⎬ ផុតវិថី

**១០.ភវង្គុបច្ឆេទ** កើត ១ ខណៈ

**១១.បញ្ចទ្វារាវជ្ជន** កើត ១ ខណៈ ជាវិថីទី ១

**១២.បញ្ចវិញ្ញាណ** កើត ១ ខណៈ ជាវិថីទី ២

**១៣.សម្បដិច្ឆន្ន** កើត ១ ខណៈ ជាវិថីទី ៣

**១៤.សន្តីរណ** កើត ១ ខណៈ ជាវិថីទី ៤

**១៥, ១៦, ១៧ ទោដ្ឋព្វន** កើត ៣ ខណៈ ជាវិថីទី ៥ ។

## ៣.បរិត្តារម្មណ៍ទី ៦

**១.អតីតភវង្គ** កើត ៩ ខណៈ

**១០.ភវង្គចលន** កើត ១ ខណៈ ⎬ ផុតវិថី

**១១.ភវង្គុបច្ឆេទ** កើត ១ ខណៈ

**១២.បញ្ចទ្វារាវជ្ជន** កើត ១ ខណៈ ជាវិថីទី ១

**១៣.បញ្ចវិញ្ញាណ** កើត ១ ខណៈ ជាវិថីទី ២

**១៤.សម្បដិច្ឆន្ន** កើត ១ ខណៈ ជាវិថីទី ៣

**១៥.សន្តីរណ** កើត ១ ខណៈ ជាវិថីទី ៤

**១៦, ១៧ ទោដ្ឋពូន** កើត ២ ខណៈ ជាវិថីទី ៥ ។

## អតបរិត្តារម្មណ៍ មាន ៦ ន័យ

**៤.អតបរិត្តារម្មណ៍ ទី ១**

**១.អតីតភវង្គ** ១០ ខណៈ

**២.ភវង្គចលន** ២ ខណៈ

**៣.ភវង្គុបច្ឆេទ** ៥ ខណៈ ។

**៤.អតបរិត្តារម្មណ៍ ទី ២**

**១.អតីតភវង្គ** ១១ ខណៈ

**២.ភវង្គចលន** ២ ខណៈ

**៣.ភវង្គុបច្ឆេទ** ៤ ខណៈ ។

**៤.អតបរិត្តារម្មណ៍ ទី ៣**

**១.អតីតភវង្គ** ១២ ខណៈ

**២.ភវង្គចលន** ២ ខណៈ

**៣.ភវង្គុបច្ឆេទ** ៣ ខណៈ ផុតវិថី។

**៤.អតបរិត្តារម្មណ៍ ទី ៤**

**១.អតីតភវង្គ** ១៣ ខណៈ

**២.ភវង្គចលន** ២ ខណៈ

**៣.ភវង្គុបច្ឆេទ** ២ ខណៈ ផុតវិថី ។

**អតបរិត្តារម្មណ៍ ទី ៥**

**១.អតីតភវង្គ** ១២ ខណៈ

**២.ភវង្គចលន** ២ ខណៈ

**៣.ភវង្គុបច្ឆេទ** ៣ ខណៈ ផុតទិវិថី ។

**៤.អតបរិត្តារម្មណ៍ ទី ៦**

**១.អតីតភវង្គ** ១៥ ខណៈ

**២.ភវង្គចលន** ២ ខណៈ ផុតវិថី ។

**អនុពន្ធកមនោទ្វារវថី ឬ តទនុវត្តកមនោទ្វារវថី (អារម្មណ៍កើតតមកពីបញ្ចទ្វារ) ៤**

**១.អតីតគហណវិថី** ជាវិថីមានអារម្មណ៍ ជាអតីត

**២.សម្ហូគហណវិធី** ជាវិថីរួមអារម្មណ៍

**៣.អត្ថគហណវិធី** ជាវិថីដែលដឹងអត្ថន័យ

**៤.នាមគហណវិធី** ជាវិថីដឹងឈ្មោះ ។

ក-សោភណកាមាវចរចិត្ត ២៤ ដួង:

**មហាកុសលចិត្ត ៨ ដួង**

**១-សោមនស្សសហគតំ ញាណសម្បយុត្តំ អសង្ខារិកំ មហាកុសលចិត្តំ** មហាកុសលចិត្ត កើតរួមជាមួយនឹង សោមនស្សវេទនា ប្រកបដោយបញ្ញា មិនមានអ្នកដទៃបបួលដឹកនាំ ។

**២-សោមនស្សសហគតំ ញាណសម្បយុត្តំ សសង្ខារិកំ មហាកុសលចិត្តំ** មហាកុសលចិត្ត

កើតរួមជាមួយនឹង សោមនស្សវេទនា ប្រកបដោយបញ្ញា មានអ្នកដទៃបបួលដឹកនាំ ។

**៣-សោមនស្សសហគតំ ញាណវិប្បយុត្តំ អសង្ខារិកំ មហាកុសលចិត្តំ** មហាកុសលចិត្ត កើតរួមជាមួយនឹង សោមនស្សវេទនា ប្រាសចាកបញ្ញា មិនមានអ្នកដទៃបបួលដឹកនាំ ។

**៤-សោមនស្សសហគតំ ញាណវិប្បយុត្តំ សសង្ខារិកំ មហាកុសលចិត្តំ** មហាកុសលចិត្ត កើតរួមជាមួយនឹង សោមនស្សវេទនា ប្រាសចាកបញ្ញា មានអ្នកដទៃបបួលដឹកនាំ ។

**៥-ឧបេក្ខាសហគតំ ញាណសម្បយុត្តំ អសង្ខារិកំ មហាកុសលចិត្តំ** មហាកុសលចិត្ត

កើតរួមជាមួយនឹង ឧបេក្ខាវេទនា ប្រកបដោយបញ្ញា មិនមានអ្នកដទៃបបួលដឹកនាំ ។

**៦-ឧបេក្ខាសហគតំ ញាណសម្បយុត្តំ សសង្ខារិកំ មហាកុសលចិត្តំ** មហាកុសលចិត្ត

កើតរួមជាមួយនឹង ឧបេក្ខាវេទនា ប្រកបដោយបញ្ញា មានអ្នកដទៃបបួលដឹកនាំ ។

**៧-ឧបេក្ខាសហគតំ ញាណវិប្បយុត្តំ អសង្ខារិកំ មហាកុសលចិត្តំ** មហាកុសលចិត្ត

កើតរួមជាមួយនឹង ឧបេក្ខាវេទនា ប្រាសចាកបញ្ញា មិនមានអ្នកដទៃបបួលដឹកនាំ ។

**៨-ឧបេក្ខាសហគតំ ញាណវិប្បយុត្តំ សសង្ខារិកំ មហាកុសលចិត្តំ** មហាកុសលចិត្ត កើតរួមជាមួយនឹង ឧបេក្ខាវេទនា ប្រាសចាកបញ្ញា មានអ្នកដទៃបបួលដឹកនាំ ។

## មហាវិបាកចិត្ត ៨ ដួង

**១.សោមនស្សសហគតំ ញាណសម្បយុត្តំ អសង្ខារិកំ មហាវិបាកចិត្តំ** មហាវិបាកចិត្ត កើតរួមជាមួយនឹង សោមនស្សវេទនា ប្រកបដោយបញ្ញា មិនមានអ្នកដទៃបបួលដឹកនាំ ។

**២.សោមនស្សសហគតំ ញាណសម្បយុត្តំ សសង្ខារិកំ មហាវិបាកចិត្តំ** មហាវិបាកចិត្ត កើតរួមជាមួយនឹង សោមនស្សវេទនា ប្រកបដោយបញ្ញា មានអ្នកដទៃបបួលដឹកនាំ ។

**៣.សោមនស្សសហគតំ ញាណវិប្បយុត្តំ អសង្ខារិកំ មហាវិបាកចិត្តំ** មហាវិបាកចិត្ត កើតរួមជាមួយនឹង សោមនស្សវេទនា ប្រាសចាកបញ្ញា មិនមានអ្នកដទៃបបួលដឹកនាំ ។

**៤.សោមនស្សសហគតំ ញាណវិប្បយុត្តំ សសង្ខារិកំ មហាវិបាកចិត្តំ** មហាវិបាកចិត្ត កើតរួមជាមួយនឹង សោមនស្សវេទនា ប្រាសចាកបញ្ញា មានអ្នកដទៃបបួលដឹកនាំ ។

**៥.ឧបេក្ខាសហគតំ ញាណសម្បយុត្តំ អសង្ខារិកំ មហាវិបាកចិត្តំ** មហាវិបាកចិត្ត កើតរួមជាមួយនឹង ឧបេក្ខាវេទនា ប្រកបដោយបញ្ញា មិនមានអ្នកដទៃបបួលដឹកនាំ ។

**៦.ឧបេក្ខាសហគតំ ញាណសម្បយុត្តំ សសង្ខារិកំ មហាវិបាកចិត្តំ** មហាវិបាកចិត្ត កើតរួមជាមួយនឹង ឧបេក្ខាវេទនា ប្រកបដោយបញ្ញា មានអ្នកដទៃបបួលដឹកនាំ ។

**៧.ឧបេក្ខាសហគតំ ញាណវិប្បយុត្តំ អសង្ខារិកំ មហាវិបាកចិត្តំ** មហាវិបាកចិត្ត កើត

រួមជាមួយនឹង ឧបេក្ខាវេទនា ប្រាសចាកបញ្ញា មិនមានអ្នកដទៃបបួលដឹកនាំ ។

**៨.ឧបេក្ខាសហគតំ ញាណវិប្បយុត្តំ សសង្ខារិកំ មហាវិបាកចិត្តំ** មហាវិបាកចិត្ត កើតរួមជាមួយនឹង ឧបេក្ខាវេទនា ប្រាសចាកបញ្ញា មានអ្នកដទៃបបួលដឹកនាំ ។

## មហាកិរិយាចិត្ត ៨ ដួង

**១.សោមនស្សសហគតំ ញាណសម្បយុត្តំ អសង្ខារិកំ មហាកិរិយាចិត្តំ** មហាកិរិយាចិត្ត កើតរួមជាមួយនឹង សោមនស្សវេទនា ប្រកបដោយបញ្ញា មិនមានអ្នកដទៃបបួលដឹកនាំ ។

**២.សោមនស្សសហគតំ ញាណសម្បយុត្តំ សសង្ខារិកំ មហាកិរិយាចិត្តំ** មហាកិរិយាចិត្ត កើតរួមជាមួយនឹង សោមនស្សវេទនា ប្រកបដោយបញ្ញា មានអ្នកដទៃបបួលដឹកនាំ ។

**៣.សោមនស្សសហគតំ ញាណវិប្បយុត្តំ អសង្ខារិកំ មហាកិរិយាចិត្តំ** មហាកិរិយាចិត្ត កើតរួមជាមួយនឹង សោមនស្សវេទនា ប្រាសចាកបញ្ញា មិនមានអ្នកដទៃបបួលដឹកនាំ ។

**៤.សោមនស្សសហគតំ ញាណវិប្បយុត្តំ សសង្ខារិកំ មហាកិរិយាចិត្តំ** មហាកិរិយាចិត្ត កើតរួមជាមួយនឹង សោមនស្សវេទនា ប្រាសចាកបញ្ញា មានអ្នកដទៃបបួលដឹកនាំ ។

**៥.ឧបេក្ខាសហគតំ ញាណសម្បយុត្តំ អសង្ខារិកំ មហាកិរិយាចិត្តំ** មហាកិរិយាចិត្ត កើតរួមជាមួយនឹង ឧបេក្ខាវេទនា ប្រកបដោយបញ្ញា មិនមានអ្នកដទៃបបួលដឹកនាំ ។

**៦.ឧបេក្ខាសហគតំ ញាណសម្បយុត្តំ សសង្ខារិកំ មហាកិរិយាចិត្តំ** មហាកិរិយាចិត្ត កើតរួមជាមួយនឹង ឧបេក្ខាវេទនា ប្រកបដោយបញ្ញា មានអ្នកដទៃបបួលដឹកនាំ ។

**៧.ឧបេក្ខាសហគតំ ញាណវិប្បយុត្តំ អសង្ខារិកំ មហាកិរិយាចិត្តំ** មហាកិរិយាចិត្ត កើតរួមជាមួយនឹង ឧបេក្ខាវេទនា ប្រាសចាកបញ្ញា មិនមានអ្នកដទៃបបួលដឹកនាំ ។

**៨.ឧបេក្ខាសហគតំ ញាណវិប្បយុត្តំ សសង្ខារិកំ មហាកិរិយាចិត្តំ** មហាកិរិយាចិត្ត កើតរួមជាមួយនឹង ឧបេក្ខាវេទនា ប្រាសចាកបញ្ញា មានអ្នកដទៃបបួលដឹកនាំ ។

## ចែកកុសលចិត្តដោយឧក្កដ្ឋ និង ឱមក ៨

**១.តិហេតុកកុសល ឧក្កដ្ឋ** (ថ្នាក់ទី ១) = តិហេតុកឧក្កដ្ឋុក្កដ្ឋ

**២.តិហេតុកកុសល ឧក្កដ្ឋ** (ថ្នាក់រង) = តិហេតុកឧក្កដ្ឋោមក

**៣.តិហេតុកកុសល ឱមក** (ថ្នាក់ទី ១) = តិហេតុកឱមកុក្កដ្ឋ

**៤.តិហេតុកកុសល ឱមក** (ថ្នាក់រង) = តិហេតុកឱមកោមក

**៥.ទ្វិហេតុកកុសល ឧក្កដ្ឋ** (ថ្នាក់ទី ១) = ទ្វិហេតុកឧក្កដ្ឋុក្កដ្ឋ

**៦.ទ្វិហេតុកកុសល ឧក្កដ្ឋ** (ថ្នាក់រង) = ទ្វិហេតុកឧក្កដ្ឋោមក

**៧.ទ្វិហេតុកកុសល ឱមក** (ថ្នាក់ទី ១) = ទ្វិហេតុកឱមកុក្កដ្ឋ

**៨.ទ្វិហេតុកកុសល ឱមក** (ថ្នាក់រង) = ទ្វិហេតុកឱមកោមក ។

## កម្មស្សកតាបញ្ញា ១០ យ៉ាង

**១.អត្ថិ ទិន្នំ** យល់ថា ទានដែលគេឲ្យហើយ មានផល ។

**២.អត្ថិ យិដ្ឋំ** យល់ថា ការបូជាធំ មានផល ។

**៣.អត្ថិ ហុតំ** យល់ថា ការបូជាតូច មានផល ។

**៤.អត្ថិ សុកតទុក្កតានំ កម្មានំ វិបាកោ** យល់ថា ផលវិបាករបស់កម្ម ដែលគេធ្វើល្អធ្វើ-អាក្រក់មាន។

**៥.អត្ថិ អយំ លោកោ** យល់ថា សត្វដែលកើតក្នុង លោកនេះមាន ។

**៦.អត្ថិ បរោ លោកោ** យល់ថា សត្វដែលកើតក្នុងលោកមុខមាន ។

**៧.អត្ថិ មាតា** យល់ថា គុណមាតាមាន ។

**៨.អត្ថិ បិតា** យល់ថា គុណបិតាមាន ។

**៩.អត្ថិ សត្តា ឱបបាតិកា** យល់ថា ពួកសត្វជាឱបបាតិកកំណើតមាន ។

**១០.អត្ថិ លោកេ សមណព្រាហ្មណា សម្មគ្គតា សម្មាបដិបន្នា** យល់ថា ពួកសមណ-ព្រាហ្មណ៍ក្នុងលោក ជាអ្នកប្រព្រឹត្តល្អ ប្រតិបត្តិត្រឹមត្រូវ ដែលធ្វើឲ្យជាក់ច្បាស់នូវលោកនេះ និងលោក-ខាងមុខ ដោយប្រាជ្ញាដ៏ឧត្តមដោយខ្លួនឯង ហើយសំដែងបានមាន ។

*ឃ.រូបាវចរភូមិ មាន ១៥ ដួង:*

**រូបាវចរកុសលចិត្ត ៥ ដួង**

**១.វិតក្កវិចារបីតិសុខេកគ្គតាសហិតំ បឋមជ្ឈានកុសលចិត្តំ** បឋមជ្ឈានកុសលចិត្ត ប្រកបដោយអង្គ ៥ គឺ វិតក្កៈ វិចារៈ បីតិ សុខៈ និង ឯកគ្គតា ។

**២.វិចារបីតិសុខេកគ្គតាសហិតំ ទុតិយជ្ឈានកុសលចិត្តំ** ទុតិយជ្ឈានកុសលចិត្ត ប្រកបដោយអង្គ ៤ គឺ វិចារៈ, បីតិ, សុខៈ, និង ឯកគ្គតា ។

**៣.បីតិសុខេកគ្គតាសហិតំ តតិយជ្ឈានកុសលចិត្តំ** តតិយជ្ឈានកុសលចិត្ត ប្រកបដោយអង្គ ៣ គឺ សុខៈ បីតិ និង ឯកគ្គតា ។

**៤.សុខេកគ្គតាសហិតំ ចតុត្ថជ្ឈានកុសលចិត្តំ** ចតុត្ថជ្ឈានកុសលចិត្ត ប្រកបដោយអង្គ ២ គឺ សុខៈ និង ឯកគ្គតា ។

**៥.ឧបេក្ខេកគ្គតាសហិតំ បញ្ចមជ្ឈានកុសលចិត្តំ** បញ្ចមជ្ឈានកុសលចិត្ត ប្រកបដោយ

អង្គ ២ គឺ ឧបេក្ខា និង ឯកគ្គតា ។

## រូបាវចរវិបាកចិត្ត ៥ ដួង

**១.វិតក្កវិចារបីតិសុខេកគ្គតាសហិតំ បឋមជ្ឈានវិបាកចិត្តំ** បឋមជ្ឈានវិបាកចិត្ត ប្រកបដោយអង្គ ៥ គឺ វិតក្កៈ វិចារៈ បីតិ សុខៈ និង ឯកគ្គតា ។

**២.វិចារបីតិសុខេកគ្គតាសហិតំ ទុតិយជ្ឈានវិបាកចិត្តំ** ទុតិយជ្ឈានវិបាកចិត្ត ប្រកបដោយអង្គ ៤ គឺ វិចារៈ បីតិ សុខៈ និង ឯកគ្គតា ។

**៣.បីតិសុខេកគ្គតាសហិតំ តតិយជ្ឈានវិបាកចិត្តំ** តតិយជ្ឈានវិបាកចិត្ត ប្រកបដោយអង្គ ៣ គឺ បីតិ សុខៈ និង ឯកគ្គតា ។

**៤.សុខេកគ្គតាសហិតំ ចតុត្ថជ្ឈានវិបាកចិត្តំ** ចតុត្ថជ្ឈានវិបាកចិត្ត ប្រកបដោយអង្គ ២ គឺ សុខៈ និង ឯកគ្គតា ។

**៥.ឧបេក្ខេកគ្គតាសហិតំ បញ្ចមជ្ឈានវិបាកចិត្តំ** បញ្ចមជ្ឈានវិបាកចិត្ត ប្រកបដោយអង្គ ២ គឺ ឧបេក្ខា និង ឯកគ្គតា ។

## រូបាវចរកិរិយាចិត្ត ៥ ដួង

**១.វិតក្កវិចារបីតិសុខេកគ្គតាសហិតំ បឋមជ្ឈានកិរិយាចិត្តំ** បឋមជ្ឈានកិរិយាចិត្ត ប្រកបដោយអង្គ ៥ គឺ វិតក្កៈ វិចារៈ បីតិ, សុខៈ និង ឯកគ្គតា ។

**២.វិចារបីតិសុខេកគ្គតាសហិតំ ទុតិយជ្ឈានកិរិយាចិត្តំ** ទុតិយជ្ឈានកិរិយាចិត្ត ប្រកបដោយអង្គ ៤ គឺ វិចារៈ បីតិ សុខៈ និង ឯកគ្គតា ។

**៣.បីតិសុខេកគ្គតាសហិតំ តតិយជ្ឈានកិរិយាចិត្តំ** តតិយជ្ឈានកិរិយាចិត្ត ប្រកបដោយអង្គ ៣ គឺ បីតិ សុខៈ និង ឯកគ្គតា ។

**៤.សុខេកគ្គតាសហិតំ ចតុត្ថជ្ឈានកិរិយាចិត្តំ** ចតុត្ថជ្ឈានកិរិយាចិត្ត ប្រកបដោយអង្គ ២ គឺ សុខៈ និង ឯកគ្គតា ។

**៥.ឧបេក្ខេកគ្គតាសហិតំ បញ្ចមជ្ឈានកិរិយាចិត្តំ** បញ្ចមជ្ឈានកិរិយាចិត្ត ប្រកបដោយអង្គ ២ គឺ ឧបេក្ខា និង ឯកគ្គតា ។

**វិថី របស់រូបាវចរកុសលចិត្ត គឺៈ**

**១.ភវង្គចលន**

**២.ភវង្គុបច្ឆេទ**

**៣.មនោទ្វារាវជ្ជន**

**៤.បរិកម្ម**

**៥.ឧបចារ**

**៦.អនុលោម**

**៧.គោត្រភូ**

(៤–៧) មហាកុសលញាណសម្បយុត្ត

**៨.ឈាន** គឺ រូបាវចរកុសលចិត្ត

**ភវង្គបាត** ចិត្តជាភវង្គ ។

**អរូបជ្ឈាន របស់មន្ទបុគ្គល (បុគ្គលអ្នកដឹងយឺត) ៖**

**១.ភវង្គចលន**
**២.ភវង្គុបច្ឆេទ** } ចិត្តផុតវិថី

**៣.មនោទ្វារាវជ្ជន**

**៤.បរិកម្ម**
**៥.ឧបចារ**
**៦.អនុលោម**
**៧.គោត្រភូ** } មហាកុសលឧបេក្ខាចិត្ត

**៨.បឋមារូបជ្ឈាន** អាកាសានញ្ចាយតនកុសលចិត្ត

**៩.ភវង្គបាត** ចិត្តជាភវង្គ ។

## អាទិកម្មិកអរូបជ្ឈានវថី របស់គក្ខបុគ្គល (អ្នកត្រាស់ដឹងហើយ)

**១.ភវង្គចលន**
}ចិត្តផុតវិថី
**២.ភវង្គុបច្ឆេទ**

**៣.មនោទ្វារាវជ្ជន**

**៤.ឧបចារ**
**៥.អនុលោម** } មហាកុសលឧបេក្ខាញាណសម្បយុត្តចិត្ត ២
**៦.គោត្រភូ**

**៧.បឋមារូបជ្ឈាន** អាកាសានញ្ចាយតនកុសល

**ភវង្គបាត** ចិត្តជាភវង្គ ។

## អាយុរបស់សត្វក្នុងកំណើតផ្សេងៗ

១.អាយុទេវតាជាន់ **ចាតុមហារាជិកា** ៥០០ ឆ្នាំទិព្វ ត្រូវជា ៩ លាន ឆ្នាំមនុស្ស ។

២.អាយុទេវតាជាន់ **តាវតិ្តង្ស** ១០០០ ឆ្នាំទិព្វ ត្រូវជា ៣៦ លាន ឆ្នាំមនុស្ស ។

៣.អាយុទេវតាជាន់ **យាមា** ២០០០ ឆ្នាំទិព្វ ត្រូវជា ១៤៤ លាន ឆ្នាំមនុស្ស ។

៤.អាយុទេវតាជាន់ **តុសិត** ៤០០០ ឆ្នាំទិព្វ ត្រូវជា ៥៧៦ លាន ឆ្នាំមនុស្ស ។

៥.អាយុទេវតាជាន់ **និម្មានរតី** ៨០០០ ឆ្នាំទិព្វ ត្រូវជា ២៣០៤ លាន ឆ្នាំមនុស្ស ។

៦.អាយុទេវតាជាន់ **បរនិម្មិតវសវតី** ១៦០០០ ឆ្នាំទិព្វ ត្រូវជា ៩២១៦ លាន ឆ្នាំមនុស្ស ។

៧.អាយុជាន់ **ព្រហ្មបារិសជ្ជា** ១ ចំហៀងកប្ប គឺ យកជអាយុ វិវដ្តដ្ឋាយិកប្ប មកបែងចេញជា ៣ ភាគ ចោល ២ ភាគ យក ១ ភាគ មកជាប្រមាណនៃអាយុព្រហ្មក្នុងជាន់ ព្រហ្មបារិសជ្ជា នោះឯង ។

៨.**ព្រហ្មបរោហិតា** មានអាយុ កន្លះវិវដ្តដ្ឋាយកប្ប ។

៩.**មហាព្រហ្ម** មានអាយុ ១ កប្ប ។

១០.**បរិត្តាព្រហ្ម** មានអាយុ ២ កប្ប ។

១១.**អប្បមាណាព្រហ្ម** មានអាយុ ៤ កប្ប ។

១២.**អាភស្សរាព្រហ្ម** មានអាយុ ៨ កប្ប ។

១៣.**បរិត្តសុភាព្រហ្ម** មានអាយុ ១៦ កប្ប ។

១៤.**អប្បមាណសុភាព្រហ្ម** មានអាយុ ៣២ កប្ប ។

១៥.**សុភកិណ្ហាព្រហ្ម** មានអាយុ ៦៤ កប្ប ។

១៦.**វេហប្ផលាព្រហ្ម** និង អសញ្ញីសត្វ មានអាយុ ៥០០ កប្ប ។

១៧.**វេហាព្រហ្ម** មានអាយុ ១០០០ កប្ប ។

១៨.**អតប្បាព្រហ្ម** មានអាយុ ២០០០ កប្ប ។

១៩.**សុទស្សាព្រហ្ម** មានអាយុ ៤០០០ កប្ប ។

២០.**សុទស្សីព្រហ្ម** មានអាយុ ៨០០០ កប្ប ។

២១.**អកនិដ្ឋកាព្រហ្ម** មានអាយុ ១៦០០០ កប្ប ។

២២.**អាកាសានញ្ចាយតនព្រហ្ម** មានអាយុ ២ មឺUន មហាកប្ប ។

២៣.**វិញ្ញាណញ្ចាយតនព្រហ្ម** មានអាយុ ៤ មឺUន មហាកប្ប ។

២៤.**អាកិញ្ចញ្ញាយតនព្រហ្ម** មានអាយុ ៦ មឺUន មហាកប្ប ។

២៥.**នេវសញ្ញានាសញ្ញាយតនព្រហ្ម** មានអាយុ ៨៤,០០០ មឺUន មហាកប្ប ។

**មហានរក ៨ រណ្ដៅ**

**១.សញ្ជីវនរក**

**២.កាឡសុត្តនរក**

**៣.សង្ឃាតនរក**

**៤.ចូឡរោរុវនរក**

**៥.មហារោរុវនរក**

**៦.តាបននរក**

**៧.មហាតាបននរក**

**៨.អវចីនរក**

**សត្វតិរច្ឆានចែកជា ៤ ពួក**

**១.អបាទតិរច្ឆាន** (សត្វឥតជើង)

**២.ទ្វិបាទតិរច្ឆាន** (សត្វជើងពីរ)

**៣.ចតុបាទតិរច្ឆាន** (សត្វជើងបួន)

**៤.ពហុបាទតិរច្ឆាន** (សត្វជើងច្រើន)

**ប្រេត ១២ ពួក**

**១.វន្តាសប្រេត** ប្រេតស៊ីរបស់ដែលគេខ្ជាក់ចេញ ។

| | |
|---|---|
| **២.កុណបាសប្រេត** | ប្រេតដែលស៊ី សាកសព ។ |
| **៣.គូថខាទប្រេត** | ប្រេតដែលស៊ីឧច្ចារៈ ។ |
| **៤.អគ្គិជាលមុខប្រេត** | ប្រេតដែលមានភ្លើងនៅក្នុងមាត់ ។ |
| **៥.សូចិមុខប្រេត** | ប្រេតដែលមានមាត់ប៉ុនម្ជុល ។ |
| **៦.តណ្ហិដ្ឋិតប្រេត** | ប្រេតដែលត្រូវសេចក្តីលំបាក បៀតបៀន ។ |
| **៧.សុនិជ្ឈាមកប្រេត** | ប្រេតដែលត្រូវឆេះខ្មៅ ដូចគល់ឈើ ។ |
| **៨.សត្ថង្គប្រេត** | ប្រេតមានក្រចក ដូចកាំបិត ។ |
| **៩.បព្វតង្គប្រេត** | ប្រេតមានកាយ ដូចភ្នំ ។ |
| **១០.អជគរង្គប្រេត** | ប្រេតមានរាងកាយ ដូចពស់ថ្លាន់ ។ |
| **១១.វិមានិកប្រេត** | ប្រេតមានវិមាន ។ |
| **១២.មហិទ្ធិកប្រេត** | ប្រេតមានឫទ្ធិច្រើន ។ |

## ប្រេត ២១ ពួក

| | |
|---|---|
| **១.អដ្ឋិសង្ខលិកប្រេត** | ប្រេតឥតមានសាច់ឈាមឡើយ ។ |
| **២.មំសបេសីប្រេត** | ប្រេតមានរាងកាយ ដូចជាចំរៀកសាច់ ។ |
| **៣.មំសបិណ្ឌិប្រេត** | ប្រេតមានរាងកាយ ដូចជាដុំសាច់ ។ |
| **៤.និច្ឆវិបុរិសប្រេត** | ប្រេតប្រុស មានរាងកាយរងាល ឥតស្បែក ។ |

**៥.អសិលោមប្រេត** ប្រេតមានដាវដោតជាប់ នឹងរាងកាយ ដូចជារោម ។

**៦.សត្តិកលោមប្រេត** ប្រេតមានលំពែងដោតជាប់ នឹងរាងកាយ ដូចជារោម ។

**៧.ឧសុលោមប្រេត** ប្រេតមានព្រួញដោតជាប់ នឹងរាងកាយ ដូចជារោម ។

**៨.សូចិលោមប្រេតទី ១** ប្រេតមានម្ជុលដោតជាប់ នឹងរាងកាយ ដូចជារោម ។

**៩.សូចិលោមប្រេតទី ២** ប្រេតមានដែកស្រួច ចាក់ខ្លាស់ច្រូងច្រាង នារាងកាយ ដូចជារោម ។

**១០.កុម្ភណ្ឌនារីប្រេត** ប្រេតមានអណ្ឌៈ (ពង) ជាភារៈធំប៉ុនឆ្នាំង ។

**១១.គូថនិមុគ្គប្រេត** ប្រេតលិចនៅក្នុងរណ្ដៅឧច្ចារៈ ។

**១២.គូថខាទកប្រេត** ប្រេតស៊ីលាមក ។

**១៣.និច្ឆវិត្ថីប្រេត** ប្រេតស្រី មានរាងកាយរងាល ឥតស្បែក ។

**១៤.មង្គុលិត្ថីប្រេត** ប្រេតស្រី មានរាងកាយអាក្រក់ គួរឲ្យខ្ពើមឆ្អើម មានក្លិនស្អុយ ។

**១៥.ឱកិលិនីប្រេត** ប្រេតស្រី មានរាងកាយឆេះរោល និងស្រោចដោយរងើកភ្លើង ។

**១៦.អសីសកពន្ធប្រេត** ប្រេតឥតក្បាល មានរាងកាយដូចសាកសពដាច់ក្បាល(មុខមាត់នៅទ្រូង)។

**១៧.ភិក្ខុប្រេត** ប្រេតភិក្ខុ មានភ្លើងឆេះសន្ធោសន្ធៅ ។

**១៨.ភិក្ខុនីប្រេត** ប្រេតភិក្ខុនី មានភ្លើងឆេះសន្ធោសន្ធៅ ។

**១៩.សិក្ខមានាប្រេត** ប្រេតសិក្ខមានា មានភ្លើងឆេះសន្ធោសន្ធៅ ។

**២០.សាមណេរប្រេត** ប្រេតសាមណេរ មានភ្លើងឆេះសន្ធោសន្ធៅ ។

**២១.សាមណេរីប្រេត** ប្រេតសាមណេរី មានភ្លើងឆេះសន្ធោសន្ធៅ ។

## **កម្ម ១៦**

**ជនកំ ឧបត្ថម្ភកំ ឧបបីឡកំ ឧបឃាតកញ្ចេតិ កិច្ចវសេន** ឈ្មោះថាកម្ម បើពោល-ដោយកិច្ច មាន ៤ យ៉ាង គឺៈ

**១.ជនកកម្ម** កម្មដែលរមែងតែងតែ ធ្វើឲ្យវិបាកកើតឡើង ។

**២.ឧបត្ថម្ភកកម្ម** កម្មដែលរមែងតែងតែ ជួយទំនុកបំរុង ។

**៣.ឧបបីឡកកម្ម** កម្មដែលចូលបៀតបៀន ។

**៤.ឧបឃាតកកម្ម** កម្មដែលចូលទៅកាត់ផ្តាច់ ។

**គរុកំ អាសន្នំ អាចិណ្ណំ កដត្តាកម្មញ្ចេតិ** បើពោលដោយលំដាប់នៃការឲ្យផល មាន ៤ យ៉ាង គឺៈ

**១.គរុកកម្ម** កម្មយ៉ាងធ្ងន់ ដែលកម្មដទៃៗ មិនអាចហាមបាន ។

**២.អាសន្នកម្ម** កម្មដែលបានធ្វើនៅពេលជិតស្លាប់ ។

**៣.អាចិណ្ណកម្ម** កម្មដែលបានសន្សំរឿយៗ ជានិច្ច ។

**៤.កដត្តាកម្ម** កម្មដែលបានធ្វើល្មមប្រមាណ ក្រៅអំពីកម្ម ៣ ខាងដើម ឬ កម្មដែលធ្លាប់ធ្វើហើយក្នុងអតីតភព ។

**ទិដ្ឋធម្មវេទនីយំ ឧបបជ្ជវេទនីយំ អបរាបរិយវេទនីយំ អហោសិកម្មញ្ចេតិ បាកកាលវសេន ចត្តារិ កម្មានិ នាម** បើពោលដោយកាលក្នុងការឲ្យផល មាន ៤ យ៉ាង គឺៈ

**១.ទិដ្ឋធម្មវេទនីយកម្ម** កម្មដែលឲ្យផលក្នុងបច្ចុប្បន្នជាតិ ។

**២.ឧបបជ្ជវេទនីយកម្ម** កម្មដែលឲ្យផលក្នុងជាតិទី ២ ។

**៣.អបរាបរិយវេទនីយកម្ម** កម្មដែលឲ្យផលក្នុងជាតិទី ៣ ជាដើម រហូតដល់ព្រះនិព្វាន ។

**៤.អហោសិកម្ម** កម្មដែលមិនឲ្យផល ។

**គថា អកុសលំ កាមាវចរកុសលំ រូបាវចរកុសលំ អរូបាវចរកុសលញ្ចេតិ បាកដ្ឋានវសេន** បើពោលដោយអំណាច នៃឋានក្នុងការឲ្យផល មាន ៤ យ៉ាង គឺ:

**១.អកុសលកម្ម** បានដល់អកុសលចេតនា ១២ ។

**២.កាមាវចរកុសលកម្ម** បានដល់មហាកុសលចេតនា ៨ ។

**៣.រូបាវចរកុសលកម្ម** បានដល់រូបាវចរកុសលចេតនា ៥ ។

**៤.អរូបាវចរកុសលចេតនា** បានដល់អរូបាវចរកុសលចេតនា ៤ ។

**ច.លោកុត្តរភូមិមាន ៤0 ដួង:**

ក-មគ្គចិត្ត ២០ ដួង:

**សោតាបត្តមគ្គជ្ឈានចិត្ត ៥ ដួង**

**១.វិតក្កវិចារបីតិសុខេកគ្គតាសហិតំ បឋមជ្ឈានសោតាបត្តិមគ្គចិត្តំ** បឋមជ្ឈានសោ-. តាបត្តិចិត្ត ប្រកបដោយ វិតក្កៈ វិចារៈ បីតិ សុខៈ និង ឯកគ្គតា ។

**២.វិចារបីតិសុខេកគ្គតាសហិតំ ទុតិយជ្ឈានសោតាបត្តិមគ្គចិត្តំ** ទុតិយជ្ឈានសោតាបត្តិ-មគ្គចិត្ត ប្រកបដោយ វិចារៈ បីតិ សុខៈ និង ឯកគ្គតា ។

**៣.បីតិសុខេកគ្គតាសហិតំ តតិយជ្ឈានសោតាបត្តិមគ្គចិត្តំ** តតិយជ្ឈានសោតាបត្តិមគ្គចិត្ត ប្រកបដោយ បីតិ សុខៈ និង ឯកគ្គតា ។

**៤.សុខេកគ្គតាសហិតំ ចតុត្ថជ្ឈានសោតាបត្តិមគ្គចិត្តំ** ចតុត្ថជ្ឈានសោតាបត្តិមគ្គចិត្ត ប្រកបដោយ សុខៈ និង ឯកគ្គតា ។

**៥.ឧបេក្ខេកគ្គតាសហិតំ បញ្ចមជ្ឈានសោតាបត្តិមគ្គចិត្តំ** បញ្ចមជ្ឈានសោតាបត្តិមគ្គចិត្ត ប្រកបដោយ ឧបេក្ខា និង ឯកគ្គតា ។

## សកទាគាមិមគ្គជ្ឈានចិត្ត ៥ ដួង

**១.វិតក្កវិចារបីតិសុខេកគ្គតាសហិតំ បឋមជ្ឈានសកទាគាមិមគ្គចិត្តំ** បឋមជ្ឈានសក-ទាគាមិមគ្គចិត្ត ប្រកបដោយ វិតក្កៈ វិចារៈ បីតិ សុខៈ និង ឯកគ្គតា ។

**២.វិចារបីតិសុខេកគ្គតាសហិតំ ទុតិយជ្ឈានសកទាគាមិមគ្គចិត្តំ** ទុតិយជ្ឈានសកទាគា-មិមគ្គចិត្ត ប្រកបដោយ វិចារៈ បីតិ សុខៈ និង ឯកគ្គតា ។

**៣.បីតិសុខេកគ្គតាសហិតំ តតិយជ្ឈានសកទាគាមិមគ្គចិត្តំ** តតិយជ្ឈានសកទាគាមិមគ្គ-ចិត្ត ប្រកបដោយ បីតិ សុខៈ និង ឯកគ្គតា ។

**៤.សុខេកគ្គតាសហិតំ ចតុត្ថជ្ឈានសកទាគាមិមគ្គចិត្តំ** ចតុត្ថជ្ឈានសកទាគាមិមគ្គចិត្ត ប្រកបដោយ សុខៈ និង ឯកគ្គតា ។

**៥.ឧបេក្ខេកគ្គតាសហិតំ បញ្ចមជ្ឈានសកទាគាមិមគ្គចិត្តំ** បញ្ចមជ្ឈានសកទាគាមិមគ្គចិត្ត ប្រកបដោយ ឧបេក្ខា និង ឯកគ្គតា ។

## អនាគាមិមគ្គជ្ឈានចិត្ត ៥ ដួង

**១.វិតក្កវិចារបីតិសុខេកគ្គតាសហិតំ បឋមជ្ឈានអនាគាមិមគ្គចិត្តំ** បឋមជ្ឈានអនាគាមិ. មគ្គចិត្ត ប្រកបដោយ វិតក្កៈ វិចារៈ បីតិ សុខៈ និង ឯកគ្គតា ។

**២.វិចារបីតិសុខេកគ្គតាសហិតំ ទុតិយជ្ឈានអនាគាមិមគ្គចិត្តំ** ទុតិយជ្ឈានអនាគាមិមគ្គ-ចិត្ត ប្រកបដោយ វិចារៈ បីតិ សុខៈ និង ឯកគ្គតា ។

**៣.បីតិសុខេកគ្គតាសហិតំ តតិយជ្ឈានអនាគាមិមគ្គចិត្តំ** តតិយជ្ឈានអនាគាមិមគ្គចិត្ត ប្រកបដោយ បីតិ សុខៈ និង ឯកគ្គតា ។

**៤.សុខេកគ្គតាសហិតំ ចតុត្ថជ្ឈានអនាគាមិមគ្គចិត្តំ** ចតុត្ថជ្ឈានអនាគាមិមគ្គចិត្ត ប្រកបដោយ សុខៈ និង ឯកគ្គតា ។

**៥.ឧបេក្ខេកគ្គតាសហិតំ បញ្ចមជ្ឈានអនាគាមិមគ្គចិត្តំ** បញ្ចមជ្ឈានអនាគាមិមគ្គចិត្ត ប្រកបដោយ ឧបេក្ខា និង ឯកគ្គតា ។

## អរហត្តមគ្គជ្ឈានចិត្ត ៥ ដួង

**១.វិតក្កវិចារបីតិសុខេកគ្គតាសហិតំ បឋមជ្ឈានអរហត្តមគ្គចិត្តំ** បឋមជ្ឈានអរហត្តមគ្គចិត្ត ប្រកបដោយ វិតក្កៈ វិចារៈ បីតិ សុខៈ និង ឯកគ្គតា ។

**២.វិចារបីតិសុខេកគ្គតាសហិតំ ទុតិយជ្ឈានអរហត្តមគ្គចិត្តំ** ទុតិយជ្ឈានអរហត្តមគ្គចិត្ត

ប្រកបដោយ វិចារៈ បីតិ សុខៈ និង ឯកគ្គតា ។

**៣.បីតិសុខេកគ្គតាសហិតំ តតិយជ្ឈានអរហត្តមគ្គចិត្តំ** តតិយជ្ឈានអរហត្តមគ្គចិត្ត ប្រកបដោយ បីតិ សុខៈ និង ឯកគ្គតា ។

**៤.សុខេកគ្គតាសហិតំ ចតុត្ថជ្ឈានអរហត្តមគ្គចិត្តំ** ចតុត្ថជ្ឈានអរហត្តមគ្គចិត្ត ប្រកបដោយ សុខៈ និង ឯកគ្គតា ។

**៥.ឧបេក្ខេកគ្គតាសហិតំ បញ្ចមជ្ឈានអរហត្តមគ្គចិត្តំ** បញ្ចមជ្ឈានអរហត្តមគ្គចិត្ត ប្រកបដោយ ឧបេក្ខា និង ឯកគ្គតា ។

ខ-ផលជ្ឈានចិត្ត ២០ ដួង:

**សោតាបត្តផលជ្ឈានចិត្ត ៥ ដួង**

**១.វិតក្កវិចារបីតិសុខេកគ្គតាសហិតំ បឋមជ្ឈានសោតាបត្តិផលចិត្តំ** បឋមជ្ឈានសោតាបត្តិផលចិត្ត ប្រកបដោយ វិតក្កៈ វិចារៈ បីតិ សុខៈ និង ឯកគ្គតា ។

**២.វិចារបីតិសុខេកគ្គតាសហិតំ ទុតិយជ្ឈានសោតាបត្តិផលចិត្តំ** ទុតិយជ្ឈានសោតាបត្តិផលចិត្ត ប្រកបដោយ វិចារៈ បីតិ សុខៈ និង ឯកគ្គតា ។

**៣.បីតិសុខេកគ្គតាសហិតំ តតិយជ្ឈានសោតាបត្តិផលចិត្តំ** តតិយជ្ឈានសោតាបត្តិផលចិត្ត

ប្រកបដោយ បីតិ សុខៈ និង ឯកគ្គតា ។

**៤.សុខេកគ្គតាសហិតំ ចតុត្ថជ្ឈានសោតាបត្តិផលចិត្តំ** ចតុត្ថជ្ឈានសោតាបត្តិផលចិត្ត ប្រកបដោយ សុខៈ និង ឯកគ្គតា ។

**៥.ឧបេក្ខេកគ្គតាសហិតំ បញ្ចមជ្ឈានសោតាបត្តិផលចិត្តំ** បញ្ចមជ្ឈានសោតាបត្តិផលចិត្ត ប្រកបដោយ ឧបេក្ខា និង ឯកគ្គតា ។

## សកទាគាមិផលជ្ឈានចិត្ត ៥ ដួង

**១.វិតក្កវិចារបីតិសុខេកគ្គតាសហិតំ បឋមជ្ឈានសកទាគាមិផលចិត្តំ** បឋមសកទាគាមិជ្ឈានចិត្ត ប្រកបដោយ វិតក្កៈ វិចារៈ បីតិ សុខៈ និង ឯកគ្គតា ។

**២.វិចារបីតិសុខេកគ្គតាសហិតំ ទុតិយជ្ឈានសកទាគាមិផលចិត្តំ** ទុតិយជ្ឈានសកទាគាមិផលចិត្ត ប្រកបដោយ វិចារៈ បីតិ សុខៈ និង ឯកគ្គតា ។

**៣.បីតិសុខេកគ្គតាសហិតំ តតិយជ្ឈានសកទាគាមិផលចិត្តំ** តតិយជ្ឈានសកទាគាមិផលចិត្ត ប្រកបដោយ បីតិ សុខៈ និង ឯកគ្គតា ។

**៤.សុខេកគ្គតាសហិតំ ចតុត្ថជ្ឈានសកទាគាមិផលចិត្តំ** ចតុត្ថជ្ឈានសកទាគាមិផលចិត្ត ប្រកបដោយ សុខៈ និង ឯកគ្គតា ។

**៥.ឧបេក្ខេកគ្គតាសហិតំ បញ្ចមជ្ឈានសកទាគាមិផលចិត្តំ** បញ្ចមជ្ឈានសកទាគាមិផលចិត្ត ប្រកបដោយ ឧបេក្ខា និង ឯកគ្គតា ។

## អនាគាមិផលជ្ឈានចិត្ត ៥ ដួង

**១.វិតក្កវិចារបីតិសុខេកគ្គតាសហិតំ បឋមជ្ឈានអនាគាមិផលចិត្តំ** បឋមជ្ឈានអនាគាមិផលចិត្ត ប្រកបដោយ វិតក្កៈ វិចារៈ បីតិ សុខៈ និង ឯកគ្គតា ។

**២.វិចារបីតិសុខេកគ្គតាសហិតំ ទុតិយជ្ឈានអនាគាមិផលចិត្តំ** ទុតិយជ្ឈានអនាគាមិផលចិត្ត ប្រកបដោយ វិចារៈ បីតិ សុខៈ និង ឯកគ្គតា ។

**៣.បីតិសុខេកគ្គតាសហិតំ តតិយជ្ឈានអនាគាមិផលចិត្តំ** តតិយជ្ឈានអនាគាមិផលចិត្ត ប្រកបដោយ បីតិ សុខៈ និង ឯកគ្គតា ។

**៤.សុខេកគ្គតាសហិតំ ចតុត្ថជ្ឈានអនាគាមិផលចិត្តំ** ចតុត្ថជ្ឈានអនាគាមិផលចិត្ត ប្រកបដោយ សុខៈ និង ឯកគ្គតា ។

**៥.ឧបេក្ខេកគ្គតាសហិតំ បញ្ចមជ្ឈានអនាគាមិផលចិត្តំ** បញ្ចមជ្ឈានអនាគាមិផលចិត្ត ប្រកបដោយ ឧបេក្ខា និង ឯកគ្គតា ។

## អរហត្តផលជ្ឈានចិត្ត ៥ ដួង

**១.វិតក្កវិចារបីតិសុខេកគ្គតាសហិតំ បឋមជ្ឈានអរហត្តផលចិត្តំ** បឋមជ្ឈានអរហត្តផលចិត្ត ប្រកបដោយ វិតក្កៈ វិចារៈ បីតិ សុខៈ និង ឯកគ្គតា ។

**២.វិចារបីតិសុខេកគ្គតាសហិតំ ទុតិយជ្ឈានអរហត្តផលចិត្តំ** ទុតិយជ្ឈានអរហត្តផលចិត្ត ប្រកបដោយ វិចារៈ បីតិ សុខៈ និង ឯកគ្គតា ។

**៣.បីតិសុខេកគ្គតាសហិតំ តតិយជ្ឈានអរហត្តផលចិត្តំ** តតិយជ្ឈានអរហត្តផលចិត្ត ប្រកបដោយ បីតិ សុខៈ និង ឯកគ្គតា ។

**៤.សុខេកគ្គតាសហិតំ ចតុត្ថជ្ឈានអរហត្តផលចិត្តំ** ចតុត្ថជ្ឈានអរហត្តផលចិត្ត ប្រកបដោយ សុខៈ និង ឯកគ្គតា ។

**៥.ឧបេក្ខេកគ្គតាសហិតំ បញ្ចមជ្ឈានអរហត្តផលចិត្តំ** បញ្ចមជ្ឈានអរហត្តផលចិត្ត ប្រកបដោយ ឧបេក្ខា និង ឯកគ្គតា ។

**អរូបាវចរចិត្ត របស់ព្រះអរហន្ត កើត**

**១.ភវង្គចលន**
**២.ភវង្គុបច្ឆេទ** } ចិត្តផុតវិថី

**៣.មនោទ្វារាវជ្ជន**

**៤.បរិកម្ម**
**៥.ឧបចារ**
**៦.អនុលោម**
**៧.គោត្រភូ** } មហាកិរិយាឧបេក្ខាញាណសម្បយុត្តចិត្ត ២

**៨.អរូបាវចរកិរិយាចិត្ត**

**ភវង្គបាត** ចិត្តជាភវង្គ ។

## លោកិយឈានសមាបត្តិមាន ២ យ៉ាង

**១.អាទិកម្មិកឈានវិថីរបស់មន្ទបុគ្គលជាទន្ធាភិញ្ញា** (ត្រាស់ដឹងយឺត) មានកាមជវ័ន កើត ៤ ខណៈ មាន ៦ វិថីៈ

1-**ភវង្គចលន** ១ ខណៈ ផុតវិថី

2-**ភវង្គុបច្ឆេទ** ១ ខណៈ ផុតវិថី

3-**មនោទ្វារាវជ្ជន** ១ ខណៈ ផុតវិថី

4-**បរិកម្ម** ១ ខណៈ ជាវិថីទី ២

5-**ឧបចារ** ១ ខណៈ ជាវិថីទី ៣

6-**អនុលោម** ១ ខណៈ ជាវិថីទី ៤

7-**គោត្រភូ** ១ ខណៈ ជាវិថីទី ៥

8-**ឈាន** ១ ខណៈ ជាវិថីទី ៦

**ភវង្គបាត** ប្រព្រឹត្តទៅក្នុងក្រសែនៃភវង្គ ។

**២.អាទិកម្មិកឈានវិថី របស់តិក្ខបុគ្គលជាខិប្បាភិញ្ញា** (ត្រាស់ដឹងរហ័ស) មានកាមជវ័ន កើត ៣ ខណៈ (មិនមានបរិកម្ម) មានវិថីកើតបាន ៥ វិថីៈ

1-**ភវង្គចលន** ១ ខណៈ ផុតវិថី

2-**ភវង្គុបច្ឆេទ** ១ ខណៈ ផុតវិថី

3-**មនោទ្វារាវជ្ជន** ១ ខណៈ ជាវិថីទី ១

4-**ឧបចារ** ១ ខណៈ ជាវិថីទី ២

5-**អនុលោម** ១ ខណៈ ជាវិថីទី ៣

6-**គោត្រភូ** ១ ខណៈ ជាវិថីទី ៤

7-**ឈាន** ១ ខណៈ ជាវិថីទី ៥

**ភវង្គបាត** ប្រព្រឹត្តទៅក្នុងក្រសែនៃភវង្គ ។

## លោកុត្តរវិថី មាន ២ យ៉ាង

**១.មគ្គវិថីរបស់មន្ទបុគ្គល មានវិថីត្រាស់ដឹងកើតបាន ៧ វិថី:**

1-**ភវង្គចលន** ១ ខណៈ ផុតវិថី

2-**ភវង្គុបច្ឆេទ** ១ ខណៈ ផុតវិថី

3-**មនោទ្វារាវជ្ជន** ១ ខណៈ ផុតវិថី ១

4-**បរិកម្ម** ១ ខណៈ ជាវិថីចិត្តទី ២

5-**ឧបចារ** ១ ខណៈ ជាវិថីចិត្តទី ៣

6-**អនុលោម** ១ ខណៈ ជាវិថីចិត្តទី ៤

7-**គោត្រភូ** ១ ខណៈ ជាវិថីចិត្តទី ៥

8-**មគ្គ** ១ ខណៈ ជាវិថីចិត្តទី ៦

9-10-**ផល** ២ ខណៈ ជាវិថីចិត្តទី ៧

**ភវង្គបាត** ចិត្តប្រព្រឹត្តទៅក្នុងក្រសែនៃភវង្គ ។

**២.វិធីរបស់តិក្ខបុគ្គល អ្នកត្រាស់ដឹងរហ័ស:**

1-**ភវង្គចលន** ១ ខណៈ ចិត្តផុតវិថី

2-**ភវង្គុបច្ឆេទ** ១ ខណៈ ចិត្តផុតវិថី

3-**មនោទ្វារាវជ្ជន** ១ ខណៈ ជាវិថីទី ១

4-**ឧបចារ** ១ ខណៈ ជាវិថីទី ២

5-**អនុលោម** ១ ខណៈ ជាវិថីទី ៣

6-**គោត្រភូ** ១ ខណៈ ជាវិថីទី ៤

7-**មគ្គ** ១ ខណៈ ជាវិថីទី ៥

8-10-**ផល** ៣ ខណៈ ជាវិថីទី ៦

**ភវង្គបាត** ចិត្តផុតវិថី ។

## ផលសមាបត្តិ ៤ ប្រភេទ

**១.ផលសមាបត្តិ** របស់ព្រះសោតាបន្ន

**២.ផលសមាបត្តិ** របស់ព្រះសកទាគាមិ

**៣.ផលសមាបត្តិ** របស់ព្រះអនាគាមិ

**៤.ផលសមាបត្តិ** របស់ព្រះអរហន្ត

ផលសមាបត្តិនីមួយៗ មាន ៥ យ៉ាង ដោយអំណាចនៃឈាន ៥ មានបឋមជ្ឈានជាដើម ទើប

ជាផលចិត្ត រួម ២០ ។ ផលសមាបត្តិវិថីនេះ កើតបានក្នុងរូបភូមិ កាមភូមិ តែក្នុងអរូបភូមិ មិនមាន សោតាបត្តិផលវិថី ក្នុងសុទ្ធាវាសភូមិ មិនមានសោតាបត្តិផលវិថី និងមិនមានសកទាគាមិផលវិថីកើតឡើង ព្រោះជាភូមិរបស់ព្រះអនាគាមី ។

ក្នុងផលសមាបត្តិវិថីនោះ ឧបចារសមាធិជវ៍ន ដែលកើតឡើង ៣ ឬ ៤ ខណៈ ហៅថា អនុលោមញាណរបស់ផលសមាបត្តិ មិនហៅថា គោត្រភូ សូម្បីក្នុងគម្ពីរមហាបដ្ឋាន ក៏ព្រះសម្ពុទ្ធត្រាស់ថា

អនុលោមរបស់ព្រះអរហន្ត (ជាបច្ច័យ) នៃផលសមាបត្តិ ដោយអនន្តរប្បច្ច័យ អនុលោមរបស់ពួកសេក្ខបុគ្គ. ល (ជាបច្ច័យ) នៃផលសមាបត្តិ ដោយអនន្តរប្បច្ច័យ ដូច្នេះ ។ អនុលោម ៣ ឬ ៤ ជវ៍ននោះ មានសង្ខារជាអារម្មណ៍ផ្សេងអំពីមគ្គវិថី អាវជ្ជនរបស់មគ្គចិត្ត គឺ គោត្រភូ មានព្រះនិព្វានជាអារម្មណ៍ ព្រោះក្នុងមគ្គវិថី ជាវិថីធ្វើឲ្យសត្វផុតទុក្ខ ចំណែកផលសមាបត្តិវិថី ជាវិថីរបស់ព្រះអរិយៈដែលពួនសម្ងំ ដើម្បី នៅជាសុខ ក្នុងបច្ចុប្បន្នភពនេះប៉ុណ្ណោះ ផលចិត្តក្នុងមគ្គវិថីនោះ មិនហៅថា ផលសមាបត្តិ ព្រោះមិនមាន បរិកម្ម និងផលចិត្តនោះកើតឡើង ២ ឬ ៣ ខណៈ ដោយអំណាចអានុភាពនៃមគ្គ តែផលសមាបត្តិនេះ មិនជាប់នឹងអរិយមគ្គ ព្រោះមានបរិកម្ម ដោយចំពោះទើបកើតឡើង ផលសមាបត្តិ ក៏គឺ ផលជវ៍នដែលកើត តជាប់គ្នាន៎ុះឯង ។

## រូបវថីនិរោធសមាបត្ត

ក្នុងវិថីនិរោធសមាបត្តិនោះ មាននេវសញ្ញានាសញ្ញាយតនជ្ឈាន កើតឡើងមុន ដូចវារៈវិថី តទៅៈ

**១.ភវង្គចលន** ១ ខណៈ ផុតវិថី

**២.ភវង្គុបច្ឆេទ** ១ ខណៈ ផុតវិថី

**៣.មនោទ្វារាវជ្ជន** ១ ខណៈ ១ វិថី

**៤.បរិកម្ម** ១ ខណៈ ១ វិថី

**៥.ឧបចារ** ១ ខណៈ ១ វិថី

**៦.អនុលោម** ១ ខណៈ ១ វិថី

**៧.គោត្រភូ** ១ ខណៈ ១ វិថី

**៨-៩-នេវសញ្ញា** ២ ខណៈ ១ វិថី

**១០.និរោធ** រលត់សញ្ញា វេទនា (មិនមានចិត្ត)

**១១.ផលចិត្ត** ១ ខណៈ ១ វិថី (ចេញចាកនិរោធ)

**១២.ភវង្គបាត** ប្រព្រឹត្តទៅក្នុងភវង្គតាមដើម ។

## វិសុទ្ធិ ៧

**១.សីលវិសុទ្ធិ** បរិសុទ្ធិដោយសីល ។

**២.ចិត្តវិសុទ្ធិ** បរិសុទ្ធិដោយចិត្ត ។

**៣.ទិដ្ឋិវិសុទ្ធិ** បរិសុទ្ធិដោយទិដ្ឋិ ។

**៤.កង្ខាវិតរណវិសុទ្ធិ** បរិសុទ្ធិព្រោះឈានកន្លងសេចក្តីសង្ស័យទាំង ១៦ ។

**៥.មគ្គាមគ្គញ្ញាណទស្សនវិសុទ្ធិ** បរិសុទ្ធិនៃមគ្គញ្ញាណទស្សន ។

**៦.បដិបទាញ្ញាណទស្សនវិសុទ្ធិ** បរិសុទ្ធិនៃបដិបទាញ្ញាណទស្សន ។

**៧.ញាណទស្សនវិសុទ្ធិ** បរិសុទ្ធិនៃញាណទស្សន ។

## វិបស្សនាញាណ ១៦

**១.នាមរូបបរិច្ឆេទញាណ** ការដឹងក្នុងការចែកនាមរូប ។

**២.នាមរូបបច្ចយបរិគ្គហញាណ** ការដឹងបច្ច័យរបស់នាមរូប ។

**៣.សម្មសនញ្ញាណ** ការឃើញនាមរូប ស្ថិតនៅក្នុងត្រៃលក្ខណ៍ ។

**៤.ឧទយព្វញ្ញាណ** ឃើញនាមរូបកើតរលត់ ។

**៥.ភង្គញ្ញាណ** ឃើញនាមរូបរលត់ទៅៗ ។

**៦.ភយតូបដ្ឋានញ្ញាណ** ឃើញនាមរូបរលត់ទៅ ជាភ័យ ។

**៧.អាទីនវញ្ញាណ** ឃើញនាមរូបរលត់ទៅៗ ជាទុក្ខ ជាទោស ។

**៨.និព្វិទាញាណ** ឃើញនាមរូបរលត់ទៅៗ គួរនឿយណាយ ។

**៩.មុញ្ចិតុកម្យតាញាណ** ឃើញនាមរូបរលត់ទៅៗ ប្រាថ្នានឹងរត់ជៀសឲ្យផុត ។

**១០.បដិសង្ខាញាណ** ឃើញនាមរូបកើតរលត់ទៅៗ រកផ្លូវរត់ចោល ។

**១១.សង្ខារុបេក្ខាញាណ** ឃើញនាមរូបរលត់ទៅៗ រកផ្លូវរត់ រត់មិនផុត នៅព្រងើយៗ ។

**១២.អនុលោមញាណ** ឃើញនាមរូមរលត់ទៅៗ មានកម្លាំងលើសឡើង តាមអំណាចរបស់អរិយសច្ច ។

**១៣.គោត្រភូញ្ញាណ** ដឹងព្រះនិព្វាន អាចទម្លាយគោត្របុថុជ្ជន ។

**១៤.មគ្គញ្ញាណ**

**១៥.ផលញ្ញាណ**

**១៦.បច្ចវេក្ខណញ្ញាណ** ញាណកើតឡើង ពិចារណាឃើញ មគ្គ ផល និព្វាន កិលេសដែលសល់ និង កិលេសដែលលះហើយ ។

## ទបស្សនូបកលេស ១០

**១.ឱភាសោ** រស្មីភ្លឺស្វាង កើតឡើងអំពី វិបស្សនា ។

**២.បីតិ** សេចក្តីឆ្អែតកាយ ឆ្អែតចិត្ត កើតភ្លៀវក្លា ជាងអំពីមុន ។

**៣.បស្សទ្ធិ** សេចក្តីរម្ងាប់កាយ រម្ងាប់ចិត្ត កើតភ្លៀវក្លា ជាងអំពីមុន ។

**៤.អធិមោក្ខោ** សទ្ធិន្ទ្រីយ៍យាងចុះ មានកម្លាំងភ្លៀវក្លា ។

**៥.បគ្គហោ** ព្យាយាមភ្លៀវក្លា អាចឲ្យសម្រេចសម្មប្បធាន ។

**៦.សុខំ** សេចក្តីសុខកើតឧត្តមក្រៃលែង ។

**៧.ញាណំ** បញ្ញាក្នុងគ្រានោះ កើតភ្លៀវក្លា ដូចព្រះខន្ធកែវវជីរៈ របស់ព្រះអម្រិន្ទ្រាធិរាជ ។

**៨.ឧបដ្ឋានំ** សតិចូលទៅតាំងមាំមួន ភ្លៀវក្លាកើតជាសតិប្បដ្ឋាន ។

**៩.ឧបេក្ខា** ឧបេក្ខាកើតភ្លៀវក្លា ជាឧបេក្ខាសម្ពោជ្ឈង្គ ។

**១០.និកន្តិ** សេចក្តីប្រាថ្នា គឺ សុខុមតណ្ហា ឲ្យយោគាវចរ មានសេចក្តីត្រេកអរក្នុងរូបនិមិត្ត ។

## ហេតុនាំឲ្យកេត លោភ: មាន ៤ យ៉ាង:

**១.លោភបរិវារកម្មបដិសន្ធិកតា** បដិសន្ធិដោយកម្ម ដែលមានលោភៈជាបរិវារ ។

**២.លោភឧស្សន្នភវតោចវនតា** ចុតិមកអំពីភព ដែលមានលោភៈច្រើន ។

**៣.ឥដ្ឋារម្មណសមាយោគោ** បានប្រសប់ជាមួយនឹងអារម្មណ៍ ដែលល្អៗរឿយៗ ។

**៤.អស្សាទទស្សនំ** បានឃើញរបស់ ដែលជាទីពេញចិត្ត ។

**ហេតុនាំឲ្យកើតមិច្ឆាទិដ្ឋិ មាន ៥ យ៉ាង:**

**១.សស្សតឧច្ឆេទទិដ្ឋជ្ឈាសយតា** ជាអ្នកមានសស្សតទិដ្ឋិ និង ឧច្ឆេទទិដ្ឋិ ជាអធ្យាស្រ័យ ។

**២.ទិដ្ឋិវិប្បន្នបុគ្គលសេវនា** សេពគប់ជាមួយនឹងបុគ្គល ដែលមានសេចក្តីយល់ឃើញខុស ។

**៣.សទ្ធម្មវិមុខតា** បែរខ្នងឲ្យព្រះសទ្ធម្ម ។

**៤.មិច្ឆាវិតក្កពហុលតា** ជាអ្នកច្រើនទៅដោយ ការគិតខុស ។

**៥.អយោនិសោ ឧម្មុជ្ជនំ** ជាអ្នកលិចចុះក្នុងការតាំងចិត្តខុស ។

**ហេតុនាំឲ្យកើតលោភៈមូលសោមនស្ស មាន ៤ យ៉ាង:**

**១.សោមនស្សបដិសន្ធិកតា** មានបដិសន្ធិចិត្ត ជាសោមនស្ស ។

**២.អគម្ភីរបកតិតា** មិនមានសេចក្តីសុខុម គម្ពីរភាព មានការគិតរាក់ជាប្រក្រតី គឺ មិនមានការ-គិតជ្រៅជ្រះ ។

**៣.ឥដ្ឋារម្មណសមាយោគោ** បានប្រសប់ជាមួយនឹងអារម្មណ៍ ដែលល្អៗ ។

**៤.ព្យសនមុត្តិ** ផុតចាកសេចក្តីវិនាស ៥ ប្រការ ។

## ព្យសន (សេចក្ដីវិនាស) ៥ ប្រការ

**១.ញាតិព្យសន** សេចក្ដីវិនាសញាតិ ឬ សាបសូន្យញាតិ ។

**២.ភោគព្យសន** សេចក្ដីវិនាសភោគទ្រព្យទាំងឡាយ ។

**៣.រោគព្យសន** សេចក្ដីវិនាសព្រោះរោគភ័យ មានជម្ងឺដង្កាត់ផ្សេងៗ ។

**៤.សីលព្យសន** សេចក្ដីវិនាសព្រោះវិបត្តិចាកសីល ។

**៥.ទិដ្ឋិព្យសន** សេចក្ដីវិនាស ដែលកើតអំពីសេចក្ដីឃើញខុសពីសម្មាទិដ្ឋិ ។

## ហេតុនាំឲ្យកើតលោភមូលឧបេក្ខា មាន ៥ ប្រការ

**១.ឧបេក្ខាបដិសន្ធិកតា** មានបដិសន្ធិជាឧបេក្ខា ។

**២.គម្ភីរបកតិតា** មានសេចក្ដីសុខុមគម្ពីរភាព មានការគិតល្អិតល្អន់ជាប្រក្រតី ។

**៣.មជ្ឈត្តារម្មណសមាយោគោ** បានប្រសប់នឹងអារម្មណ៍ ដែលជាកណ្ដាល ។

**៤.ព្យសនមុត្តិ** ផុតចាកសេចក្ដីវិនាស ៥ ប្រការ ។

**៥.មូគធាតុកតា** សន្ដានជាមនុស្សគ ។

## លះបង់កាមឆន្ទៈដោយធម៌ ៦ ប្រការ

១.ការរៀនយកនូវអសុភនិមិត្ត ។

២.ប្រកបសេចក្ដីព្យាយាមរឿយៗ ក្នុងអសុភភាវនា ។

៣.ភាពជាអ្នកគ្រប់គ្រងល្អ ក្នុងឥន្ទ្រីយ៍ ។

**៤.ភោជនេមត្តញ្ញុតា** ភាពជាអ្នកស្គាល់ប្រមាណក្នុងភោជន ។

**៥.កល្យាណមិត្តតា** ភាពជាអ្នកមានកល្យាណមិត្ត ។

**៦.សប្បាយកថា** ភាពជាអ្នកពោល ឬ ស្តាប់ពាក្យជាទីសប្បាយ ។

## ហេតុនាំឲ្យកើតទិដ្ឋិគតសម្បយុត្តចិត្ត ៤ មាន ៥ ប្រការ

**១.ទិដ្ឋជ្ឈាសយតា** មានមិច្ឆាទិដ្ឋិជាចរិតអធ្យាស្រ័យ ។

**២.ទិដ្ឋិវិប្បន្នបុគ្គលសេវនតា** សេពគប់នឹងបុគ្គល ដែលជាមិច្ឆាទិដ្ឋិ ។

**៣.សទ្ធម្មវិមុខតា** មិនបានសិក្សាព្រះសទ្ធម្ម ។

**៤.មិច្ឆាវិតក្កពហុលតា** ចូលចិត្តនឹកគិតតែរឿងដែលខុសៗ ។

**៥.អយោនិសោ ឧម្មុជ្ជនំ** លិចចុះនៅក្នុងការពិចារណា ដែលមិនឆ្លាតឈ្លាស ។

## ហេតុនាំឲ្យកើតទិដ្ឋិគតវិប្បយុត្តចិត្ត ៤ មាន ៥ ប្រការ

**១.សស្សតឧច្ឆេទទិដ្ឋិអនជ្ឈាសយតា** មិនមានសស្សតទិដ្ឋិ និងឧច្ឆេទទិដ្ឋិជាចរិតអធ្យាស្រ័យ ។

**២.ទិដ្ឋិបន្នបុគ្គលអសេវតា** មិនសេពគប់នឹងមនុស្ស ដែលជាមិច្ឆាទិដ្ឋិ ។

**៣.សទ្ធម្មសម្មុខតា** បែរមុខទៅរកព្រះសទ្ធម្ម ។

**៤.សម្មាវិតក្កពហុលតា** ច្រើនទៅដោយការគិតត្រូវ គិតប្រពៃ ។

**៥.អយោនិសោ ន ឧម្មុជ្ជនំ** មិនលិចចុះនៅក្នុងការពិចារណា ដែលមិនឆ្លាតឈ្លាស ។

## ហេតុនាំឲ្យកើតអកុសលអសង្ខារិកចិត្ត មាន ៦ ប្រការ

**១.អសង្ខារិកកម្មជនិកបដិសន្ធិកតា** មានបដិសន្ធិចិត្តកើតអំពី អសង្ខារិក ។

**២.កល្លកាយចិត្តតា** មានសេចក្តីសុខកាយសុខចិត្ត (មាំមួន) ។

**៣.សីតណ្ហាទីនំខមនពហុលតា** មានសេចក្តីអត់ធន់ចំពោះត្រជាក់ និងក្តៅជាដើម ក្រីក្រធ្លាប់ឆ្លងកាត់ ។

**៤.កត្តព្វកម្មេសុទិដ្ឋានិសំសតា** ឃើញផលក្នុងការងារដែលនឹងគប្បីធ្វើ ។

**៥.កម្មេសុ ចិណ្ណាវសិតា** មានសេចក្តីស្ទាត់ជំនាញ ក្នុងការងារដែលធ្វើ ។

**៦.ឧតុភោជនាទិសប្បាយលាភោ** បានទទួលអាកាសល្អ និងការងារដែលធ្វើ ។

## ហេតុនាំឲ្យកេតទោសមូលចិត្ត មាន ៥ ប្រការ

**១.ទោសជ្ឈាសយតា** មានអធ្យាស្រ័យជាមនុស្ស តែងតែខឹងក្រោធ ។

**២.អគម្ភីរបកតិតា** មានការគិតមិនល្អិតល្អន់ ។

**៣.អប្បសុត្តា** មានការសិក្សាតិច ។

**៤.អនិដ្ឋារម្មណសមាយោគោ** បានជួបនឹងអារម្មណ៍ ដែលមិនល្អ ។

**៥.អាឃាតវត្ថុសមាយោគោ** បានជួបនឹងអាឃាតវត្ថុ ១០ ប្រការ ។

## អាឃាតវត្ថុ ១០ ប្រការ

**១.អាឃាតគេដោយគិតថា** បានធ្វើសេចក្តីវិនាសដល់យើង ។

**២.អាឃាតគេដោយគិតថា** កំពុងធ្វើសេចក្តីវិនាសដល់យើង ។

**៣.អាឃាតគេដោយគិតថា** នឹងធ្វើសេចក្តីវិនាសដល់យើង ។

**៤.អាឃាតគេដោយគិតថា** បានធ្វើសេចក្ដីវិនាស ដល់អ្នកដែលយើងស្រឡាញ់ យើញពេញចិត្ត ។

**៥.អាឃាតគេដោយគិតថា** កំពុងធ្វើសេចក្ដីវិនាស ដល់អ្នកដែលយើងស្រឡាញ់ យើងពេញចិត្ត ។

**៦.អាឃាតគេដោយគិតថា** នឹងធ្វើសេចក្ដីវិនាស ដល់អ្នកដែលយើងស្រឡាញ់ យើងពេញចិត្ត។

**៧.អាឃាតគេដោយគិតថា** បានធ្វើគុណប្រយោជន៍ ដល់អ្នកដែលយើងស្អប់ យើងមិនស្រឡាញ់ ។

**៨.អាឃាតគេដោយគិតថា** កំពុងធ្វើគុណប្រយោជន៍ដល់អ្នកដែលយើងស្អប់ យើងមិនស្រឡាញ់។

**៩.អាឃាតគេដោយគិតថា** នឹងធ្វើគុណប្រយោជន៍ ដល់អ្នកដែលយើងស្អប់ យើងមិនស្រឡាញ់ ។

**១០.អាឃាតកើតឡើងកន្លុងឋានៈ ដែលមិនសមគួរ** ដូចជា កើតសេចក្ដីក្រោធ កាល-ដើរទៅ ចំពប់គុលឈើ ឬជាន់បន្លាជាដើម ។

## លះបង់ព្យាបាទ ដោយធម៌ ៦ ប្រការ

**១.មេត្តានិមិត្តស្ស ឧគ្គហោ** ការរៀនយកនូវមេត្តានិមិត្ត ។

**២.មេត្តាភាវនានុយោគោ** ការប្រកបព្យាយាមរឿយៗ ក្នុងមេត្តាភាវនា ។

**៣.កម្មស្សកតាបច្ចវេក្ខណា** ការពិចារណាថា សត្វទាំងឡាយ មានកម្មជារបស់ខ្លួន ។

**៤.បដិសង្ខានពហុលីកតា** ភាពជាអ្នកច្រើនទៅដោយ ការពិចារណា ។

**៥.កល្យាណមិត្តតា** ភាពជាអ្នកមានកល្យាណមិត្ត ។

**៦.សប្បាយកថា** ការសន្ទនាដល់រឿង ដែលជាទីសប្បាយ ។

## ហេតុនាំឲ្យកើតមោហមូលចិត្ត មាន ១ ប្រការ

**១.អយោនិសោមនិការ** មិនធ្វើទុកក្នុងចិត្តដោយឧបាយនៃប្រាជ្ញា ។

## វចិកិច្ឆា មាន ២ ប្រការ

**១.និវរណាត្តកវិចិកិច្ឆា** សេចក្ដីសង្ស័យដែលចាត់ជាតួ នីវរណសុទ្ធៗ បានដល់សេចក្ដីសង្ស័យដែលជាសំយោជនៈនោះឯង ។

**២.បដិរូបបកវិចិកិច្ឆា** សេចក្ដីសង្ស័យក្លែងក្លាយ គឺ មិនចាត់ជា នីវរណសុទ្ធៗ ដូចជា

សង្ស័យក្នុងឈ្មោះមនុស្ស ក្នុងផ្លូវដើរ ជាដើម ។

## ហេតុដែលលះវចិកិច្ឆា មាន ៦ ប្រការ

**១.ពហុស្សុត្តា** ជាពហុស្សូត្រ គឺ បានឮ បានស្ដាប់ច្រើន ។

**២.បរិបុច្ឆកតា** តែងតែសាកសួគ៌រឿយៗ ។

**៣.វិនយេបកតញ្ញូតា** ចេះដឹងសព្វជំនាញ និងតឹងរឹងក្នុងវិន័យ ។

**៤.អធិមោក្ខពហុលតា** ច្រើនដោយការសម្រេចចិត្តជឿ ។

**៥.កល្យាណមិត្តតា** មានមិត្តល្អ ។

**៦.សប្បាយកថា** បានស្ដាប់ពាក្យដែលជាទីសប្បាយ ។

## ហេតុនាំឲ្យលះឧទ្ធច្ចៈ មាន ៦ ប្រការ

**១.ពហុស្សុត្តា** ជាពហុស្សូត្រ គឺ បានឮ បានស្ដាប់ច្រើន ។

**២.បរិបុច្ឆកតា** តែងតែសាកសួគ៌រឿយៗ ។

**៣.វិនយេបកតញ្ញុតា** ចេះដឹងសព្វជំនាញ និងតឹងរឹងក្នុងវិន័យ ។

**៤.ពុទ្ធសេវិតា** បានស្តាប់ធម៌របស់ព្រះពុទ្ធរឿយៗ ។

**៥.កល្យាណមិត្តតា** មានមិត្រល្អ ។

**៦.សប្បាយកថា** បានស្តាប់ពាក្យដែលជាទីសប្បាយ ។

## ហេតុនាំឲ្យកេតចក្ខុវញ្ញាណចិត្ត ២ មាន ៤ ប្រការ

**១.ចក្ខុបសាទ** មានបសាទភ្នែកល្អ ។

**២.រូបារម្មណ៍** មានរូប គឺ ពណ៌ផ្សេងៗ មកប្រាកដចំពោះមុខ ។

**៣.អាលោក** មានពន្លឺ ។

**៤.មនសិការ** មានសេចក្តីតាំងចិត្ត (បញ្ចទ្វារាវជ្ជនចិត្ត) ។

## ហេតុនាំឲ្យកេតសោតវញ្ញាណចិត្ត ២ មាន ៤ ប្រការ

**១.សោតបសាទ** មានបសាទត្រចៀកល្អ ។

**២.សទ្ទារម្មណ៍** មានសំឡេងផ្សេងៗ មកប្រាកដចំពោះមុខ ។

**៣.វិវរាកាស** មានប្រហោងត្រចៀក (មានអាកាស) ។

**៤.មនសិការ** មានសេចក្តីតាំងចិត្ត ។

## ហេតុនាំឲ្យកេតឃានវញ្ញាណចិត្ត ២ មាន ៤ ប្រការ

**១.ឃានបសាទ** មានបសាទច្រមុះល្អ ។

**២.គន្ធារម្មណ៍** មានក្លិនផ្សេងៗ មកប្រាកដចំពោះមុខ ។

**៣.វាយោធាតុ** មានធាតុខ្យល់ ។

**៤.មនសិការ** មានសេចក្ដីតាំងចិត្ត ។

## ហេតុនាំឲ្យកើតជិវ្ហាវិញ្ញាណចិត្ត ២ មាន ៤ ប្រការ

**១.ជិវ្ហាបសាទ** មានបសាទអណ្ដាតល្អ ។

**២.រសារម្មណ៍** មានរសផ្សេងៗ មកប្រាកដចំពោះមុខ ។

**៣.អាបោធាតុ** មានធាតុទឹក ។

**៤.មនសិការ** មានសេចក្ដីតាំងចិត្ត ។

## ហេតុនាំឲ្យកើតកាយវិញ្ញាណចិត្ត ២ មាន ៤ ប្រការ

**១.កាយបសាទ** មានកាយបសាទល្អ ។

**២.ផោដ្ឋព្វារម្មណ៍** មានក្ដៅ ត្រជាក់ រឹង ទន់ កំរើក ញ័រ មកប្រាកដចំពោះមុខ ។

**៣.ថទ្ធបឋវី** មានបឋវីធាតុ ដែលមានអាការៈរឹង ។

**៤.មនសិការ** មានសេចក្ដីតាំងចិត្ត ។

## ហេតុនាំឲ្យកើតមនោធាតុ ៣ មាន ៤ ប្រការ

**១.បញ្ចទ្វារ** មានបសាទទាំង ៥ មានចក្ខុជាដើម ។

**២.បញ្ចារម្មណ៍** មានអារម្មណ៍ទាំង ៥ មានរូបជាដើម ។

**៣.ហទយវត្ថុ** មានហទយវត្ថុ ជាទីតាំងនៃចិត្ត និង ចេតសិក ។

**៤.មនសិការ** មានសេចក្ដីតាំងចិត្ត ។

## ហេតុនាំឲ្យកើតមនោវិញ្ញាណធាតុ ៧៦ មាន ៤ ប្រការ

**១.មនោទ្វារ** បានដល់ ភវង្គចិត្ត ១៩ គឺ ឧបេក្ខាសន្តីរណចិត្ត ២, មហាវិបាកចិត្ត ៨, មហគ្គតវិបាកចិត្ត ៩ ។

**២.អារម្មណ៍ ៦** បានដល់រូបារម្មណ៍ ជាដើម ។

**៣.ហទយវត្ថុ** បានដល់វត្ថុហទយរូប (សម្រាប់ក្នុងបញ្ចវោការភូមិ គឺ ភូមិដែលមានខន្ធ ៥) ឬ ដែលមិនមានវត្ថុហទយរូប (សម្រាប់ក្នុងចតុវោការភូមិ គឺ ភូមិដែលមានខន្ធ ៤) ។

**៤.មនសិការ** មានសេចក្ដីតាំងចិត្ត ។

## អត្ថនៃពាក្យថាកុសល ៥ ប្រការ

**១.អារោគ្យត្ថ** ដោយអត្ថថា មិនមានរោគ គឺ មិនមានរាគៈ ជាដើម ។

**២.សន្ធរត្ថ** ដោយអត្ថថា ល្អស្អាត គឺ ជួយគាំទ្រដល់សត្វទាំងឡាយ ។

**៣.ឆេកត្ថ** ដោយអត្ថថា ឆ្លាតឈ្លាស ។

**៤.អនវជ្ជត្ថ** មិនមានទោសដែលនឹងគប្បីតិះដៀលបាន ។

**៥.សុខវិបាកត្ត** ដោយអត្ថថា ឲ្យផលជាសុខ ។

## ហេតុនាំឲ្យកើតមហាកុសល មាន ៥ ប្រការ

**១.បុព្វេ ច កតបុញ្ញតា** ធ្លាប់ធ្វើបុណ្យទុកពីកាលមុន ។

**២.បដិរូបទេសវាស** នៅក្នុងប្រទេសដ៏សមគួរ ។

**៣.សប្បុរិសូបនិស្សយ** សេពគប់នឹងសប្បុរស ។

**៤.សទ្ធម្មស្សវន** ស្តាប់ធម៌របស់សប្បុរស ។

**៥.អត្តសម្មាបណិធិ** តាំងខ្លួនទុកដោយប្រពៃ ។

## ហេតុនាំឲ្យកើតមហាកុសលសោមនស្ស មាន ៦ ប្រការ

**១.សោមនស្សបដិសន្ធិកតា** មានបដិសន្ធិចិត្ត ជាសោមនស្ស ។

**២.សទ្ធាពហុលតា** មានសទ្ធាច្រើន ។

**៣.វិសុទ្ធទិដ្ឋិតា** មានសេចក្តីយល់ឃើញត្រឹមត្រូវ អស់មន្ទិល ។

**៤.អានិសំសទស្សាវិតា** ឃើញអានិសង្សនៃកុសលកម្មនោះៗ ។

**៥.ឥដ្ឋារម្មណសមាយោគោ** បានជួបនឹងឥដ្ឋារម្មណ៍ គឺ បានទេយ្យធម៌ និង បដិគ្គាហកៈ ដែលជាទីពេញចិត្ត ។

**៦.កស្សចិបីឡាភាវោ** មិនមានឧបសគ្គណាៗ រារាំង ។

## ហេតុនាំឲ្យកើតមហាកុសលឧបេក្ខា មាន ៦ ប្រការ

**១.ឧបេក្ខាបដិសន្ធិកតា** មានបដិសន្ធិចិត្តជាឧបេក្ខា ។

**២.អប្បសទ្ធតា** មានសទ្ធាតិច ។

**៣.អវិសុទ្ធទិដ្ឋិ** មានសេចក្តីយល់ឃើញមិនបរិសុទ្ធ មានមន្ទិលលាយខ្លះ ។

**៤.អានិសំសអទស្សាវិតា** មិនឃើញ ឬ មិនយល់ក្នុងអានិសង្ស នៃកុសលកម្មនោះៗ ។

**៥.មជ្ឈត្តារម្មណសមាយោគោ** បានជួបនឹងអារម្មណ៍ជាកណ្តាល គឺ បានទេយ្យធម៌ និង បដិគ្គាហក ជាយ៉ាងកណ្តាល ។

**៦.កស្សចិបីឡិកតា** មានឧបគ្គឯណានីមួយមករារាំង ។

## ហេតុនាំឲ្យកើតមហាកុសលញ្ញាណសម្បយុត្តចិត្ត មាន ៤ ប្រការ

**១.បញ្ញាសំវត្តនិកកម្មូបនិស្សយតា** បដិសន្ធិមក ដោយអាស្រ័យកុសលកម្ម ដែលប្រកប ដោយបញ្ញា ។

**២.អព្យាបជ្ឈលោកូបបត្តិយា** កើតក្នុងជាតិ ដែលអស់សេចក្តីកង្វល់ព្រួយបារម្ភ ប្រាសចាក សេចក្តីព្យាបាទ មានឱកាសបានចូលវត្តស្តាប់ធម៌ ។

**៣.កិលេសទូរតា** ឆ្ងាយចាកកិលេស មិនចាប់អារម្មណ៍ក្នុងការស្វែងរកធម៌ ។

**៤.ឥន្ទ្រិយបរិបាកតា** មានបញ្ញិន្ទ្រីយ៍ចាស់ក្លា គឺ មានអាយុចន្លោះ ៤០ ដល់ ៥០ ឆ្នាំ ហៅថា បញ្ញាទសក ដែលជាវ័យ មានបញ្ញា ពិនិត្យពិចារណាដោយល្អិតល្អន់ ដល់ហេតុផល ។

## ន័យម្យ៉ាងទៀត ហេតុនាំឲ្យកើតមហាកុសលញ្ញាណសម្បយុត្តចិត្ត មាន ៧ ប្រការ

**១.បរិបុច្ឆកតា** តែងតែសាកសួរធម៌រឿយៗ ។

**២.វត្ថុវិសទកិរិយា** ស្អាតទាំងកាយទាំងចិត្ត រហូតដល់គ្រឿងប្រើប្រាស់ ។

**៣.ឥន្ទ្រិយសមន្តបដិវជ្ជនា** រក្សាឥន្ទ្រីយ៍ ៥ មានសទ្ធាជាដើម ។

**៤.ទុប្បញ្ញបុគ្គលបរិវជ្ជនា** គេចចេញឲ្យផុតអំពីបុគ្គល ដែលមិនមានបញ្ញា ។

**៥.បញ្ញវន្តបុគ្គលសេវនា** សេពគប់នឹងបុគ្គលជាបណ្ឌិត ។

**៦.គម្ភីរញាណចរិយបច្ចវេក្ខណា** ពិចារណាធម៌ដ៏ជម្រៅ ។

**៧.តទធិមុត្តតា** បង្អោនចិត្តស្វែងរកសនៃធម៌ ដែលជញ្ជឹងគិត ដែលធ្វើត្រូវឲ្យកើតបញ្ញា ។

## ហេតុនាំឲ្យកើតមហាកុសលញាណវិប្បយុត្តចិត្ត មាន ៤ ប្រការ

**១.បញ្ញាអសំវត្តនិកកម្មូបនិស្សយតា** បដិសន្ធិមកដោយមិនបានអាស្រ័យកុសលកម្ម ដែលប្រកបដោយបញ្ញា ។

**២.សព្យាបជ្ឈលោកូបបត្តិយា** កើតក្នុងជាតិដែលមិនអស់សេចក្តីកង្វល់ ព្រួយបារម្ភនៅពេញទៅដោយការព្យាបាទ ។

**៣.កិលេសាទូរតា** មិនធ្វើចិត្តឲ្យឆ្ងាយចាកកិលេស នៅចាប់អារម្មណ៍ក្នុងការស្វែងរកកិលេសធម៌ ។

**៤.ឥន្ទ្រិយអបរិបាកតា** មានបញ្ចិន្ទ្រីយ៍ នៅមិនទាន់ចាស់ក្លា ព្រោះសេចក្តីប្រមាទក្នុងវ័យ ។

## ចេតសិកបរមត្ថ ៥២ ដួង

### ក-អញ្ញសមានាចេតសិក ១៣ ដួង:

**ផស្សោ** ប៉ះអារម្មណ៍, **វេទនា** សោយអារម្មណ៍, **សញ្ញា** សម្គាល់អារម្មណ៍, **ចេតនា** គិតចាត់ចែងអារម្មណ៍, **ឯកគ្គតា** ផ្គងចិត្តឲ្យមានអារម្មណ៍តែមួយ, **ជីវិតិន្ទ្រិយំ** ញុំាងសហជាតធម៌ឲ្យរស់

នៅ, **មនសិការោ** ធ្វើទុកក្នុងចិត្ត, **វិតក្កោ** ត្រិះរិះអារម្មណ៍, **វិចារោ** ពិចារណានូវអារម្មណ៍, **អធិមោក្ខោ** ចុះស៊ុបក្នុងអារម្មណ៍, **វីរិយ** ព្យាយាម, **បីតិ** ឆ្អែតក្នុងកាយក្នុងចិត្ត, **ឆន្ទោ** បំណងក្នុងអារម្មណ៍។

ខ-អកុសលចេតសិក ១៤ ដួង:

**មោហោ** វង្វេងក្នុងអារម្មណ៍, **អហិរិកំ** មិនខ្មាសបាប, **អនោត្តប្បំ** មិនតក់ស្លុតក្នុងបាប, **ឧទ្ធច្ចំ** រវើរវាយក្នុងអារម្មណ៍, **លោភោ** ជាប់ជំពាក់ក្នុងអារម្មណ៍, **ទិដ្ឋិ** ការយល់ខុស, **មានោ** រឹងត្អឹង, **ទោសោ** ប្រទូស្តក្នុងអារម្មណ៍, **ឥស្សា** ច្រណែន, **មច្ឆរិយំ** កំណាញ់, **កុក្កុច្ចំ** ក្តៅក្រហាយស្តាយក្រោយ, **ថីនំ** រួញរាចំពោះកុសល, **មិទ្ធំ** ងងុយងោកងក់, **វិចិកិច្ឆា** សង្ស័យ ។

គ-សោភណចេតសិក ២៥ ដួង:

**សទ្ធា** ជឿកម្មផល, **សតិ** រលឹកដឹងខុសត្រូវ, **ហិរិ** ខ្មាសបាប, **ឱត្តប្ប** តក់ស្លុតក្នុងអំពើបាប, **អលោភោ** មិនជាប់ជំពាក់, **អទោសោ** មិនប្រទូស្ត, **តត្រមជ្ឈត្តតា** សម្លឹងកណ្តាល, **កាយបស្សទ្ធិ** ស្ងប់កាយ, **ចិត្តបស្សទ្ធិ** ស្ងប់ចិត្ត, **កាយលហុតា** ស្រាលកាយ, **ចិត្តលហុតា** ស្រាលចិត្ត, **កាយមុទុតា** ទន់ភ្លន់កាយ, **ចិត្តមុទុតា** ទន់ភ្លន់ចិត្ត, **កាយកម្មញ្ញតា** កាយគួរដល់ការងារ, **ចិត្តកម្មញ្ញតា** ចិត្តគួរដល់ការងារ, **កាយបាគុញ្ញតា** កាយស្ទាត់ជំនាញ, **ចិត្តបាគុញ្ញតា** ចិត្តស្ទាត់ជំនាញ, **កាយុជុកតា** កាយត្រឹមត្រូវ, **ចិត្តុជុកតា** ភាវៈនៃចិត្តត្រង់, **សម្មាវាចា** សម្តីប្រពៃ, **សម្មាកម្មន្តោ** ការងារប្រពៃ, **សម្មាអាជីវោ** អាជីវៈប្រពៃ, **ករុណា** អាណិត, **មុទិតា** ទន់ភ្លន់, **បញ្ញិន្ទ្រិយំ** ភាវៈជាធំក្នុងការចេះដឹង គឺបញ្ញា ។

-**សព្វចិត្តសាធារណចេតសិក** ៧ គឺៈ  ផស្សោ, វេទនា, សញ្ញា, ចេតនា, ឯកគ្គតា, ជីវិតិន្ទ្រិយំ, មនសិការោ ។

-**បកិណ្ណកចេតសិក** ៦ គឺៈ វិតក្កោ, វិចារោ, អធិមោក្ខោ, វីរិយំ, បីតិ, ឆន្ទោ ។

-**សោភណសាធារណចេតសិក** ១៩ គឺៈ សទ្ធា, សតិ, ហិរិ, ឱត្តប្ប, អលោភោ, អទោសោ, តត្រមជ្ឈត្តតា, កាយបស្សទ្ធិ, ចិត្តបស្សទ្ធិ, កាយលហុតា, ចិត្តលហុតា, កាយមុទុតា, ចិត្តមុទុតា, កាយកម្មញ្ញតា, ចិត្តកម្មញ្ញតា, កាយបាគុញ្ញតា, ចិត្តបាគុញ្ញតា, កាយុជុកតា, ចិត្តុជុកតា ។

-**វិរតិ** ៣ គឺៈ សម្មាវាចា, សម្មាកម្មន្តោ, សម្មាអាជីវោ ។

-**អប្បមញ្ញាចេតសិក** ២ គឺៈ ករុណា, មុទិតា ។

-**បញ្ញិន្ទ្រិយចេតសិក** ១ គឺៈ បញ្ញិន្ទ្រិយំ ។

- **សព្វចិត្តសាធារណចេតសិក** ៧ ប្រកបក្នុងចិត្តទាំងអស់ ៨៩ ឬ ១២១ ។
- **វិតក្កចេតសិក** ប្រកបបានក្នុងចិត្ត ៥៥ ដួង គឺ កាមចិត្ត ៤៤ (វៀរទ្វិបញ្ចវិញ្ញាណចិត្ត ១០ ), បឋមជ្ឈានចិត្ត ១១ ។
- **វិចារចេតសិក** ប្រកបបានក្នុងចិត្ត ៦៦ គឺ កាមចិត្ត ៤៤ (វៀរទ្វិបញ្ចវិញ្ញាណចិត្ត១០), បឋមជ្ឈានចិត្ត ១១, ទុតិយជ្ឈានចិត្ត ១១ ។
- **អធិមោក្ខចេតសិក** ប្រកបបានក្នុងចិត្ត ១១០ គឺ កាមចិត្ត ៤៣ (វៀរទ្វិបញ្ចវិញ្ញាណចិត្ត ១០, វិចិកិច្ឆាសម្បយុត្តចិត្ត ១), មហគ្គតចិត្ត ២៧, លោកុត្តរចិត្ត ៤០ ។
- **វីរិយចេតសិក** ប្រកបបានក្នុងចិត្ត ១០៥ គឺ កាមចិត្ត ៣៨ (វៀរអហេតុកវិបាកចិត្ត១៥,

បញ្ចទ្វារាវជ្ជនចិត្ត ១), មហគ្គតចិត្ត ២៧, លោកុត្តរចិត្ត ៤០ ។

➢ **បីតិចេតសិក** ប្រកបបានក្នុងចិត្ត ៥១ គឺ កាមសោមនស្សសហគ្គតចិត្ត ១៨, បឋមជ្ឈាន ចិត្ត ១១, ទុតិយជ្ឈានចិត្ត ១១, តតិយជ្ឈានចិត្ត ១១ ។

➢ **ឆន្ទចេតសិក** ប្រកបបានក្នុងចិត្ត ១០១ គឺ កាមចិត្ត ៣៤ (វៀរមោហមូលចិត្ត ២, អហេតុកចិត្ត ១៨, មហគ្គតចិត្ត ២៧, លោកុត្តរចិត្ត ៤០ ។

(ចប់សម្បយោគន័យអញ្ញសមានាចេតសិក ១៣)

- **មោចតុកចេតសិក** ៤ ប្រកបបានក្នុងអកុសលចិត្ត ១២ ទាំងអស់ ។

- **លោតិកចេតសិក ៣ គឺ:**

-**លោភចេតសិក** ប្រកបបានក្នុងលោភមូលចិត្ត ៨ ។

-**ទិដ្ឋិចេតសិក** ប្រកបបានក្នុងទិដ្ឋិគតសម្បយុត្តចិត្ត ៤ ។

-**មានចេតសិក** ប្រកបបានក្នុងទិដ្ឋិគតវិប្បយុត្តចិត្ត ៤ ។

- **ទោចតុកចេតសិក** ៤ ប្រកបបានក្នុងទោសមូលចិត្ត ២ ។
- **ថីនុកចេតសិក** ២ ប្រកបបានក្នុងអកុសលសសង្ខារិកចិត្ត ៥ ។
- **វិចិកិច្ឆាចេតសិក** ១ ប្រកបបានក្នុងវិចិកិច្ឆាសម្បយុត្តចិត្ត ១ ។

(ចប់អកុសលចេតសិក ១៤)

➢ **សោភណសាធារណចេតសិក** ១៩ ប្រកបបានក្នុងសោភណចិត្តទាំងអស់ ៥៩ ឬ ៩១។

➢ **ទិរតិចេតសិក** ៣ ប្រកបបានក្នុងចិត្ត ១៦ ឬ ៤៨ គឺ មហាកុសលចិត្ត ៨, លោកុត្តរចិត្ត ៨ ឬ ៤០ ។

➢ **អប្បមញ្ញាចេតសិក** ២ ប្រកបបានក្នុងចិត្ត ២៨ គឺ មហាកកុសលចិត្ត ៨, មហាកិរិយាចិត្ត ៨, រូបាវចរចិត្ត ១២ (វៀរបញ្ចមជ្ឈានចិត្ត ៣) ។

➢ **បញ្ញាចេតសិក** ១ ប្រកបបានក្នុងចិត្ត ៤៧ ឬ ៧៩ គឺ មហាកុសលញាណសម្បយុត្តចិត្ត ៤, មហាវិបាកញាណសម្បយុត្តចិត្ត ៤, មហាកិរិយាញាណសម្បយុត្តចិត្ត ៤, មហគ្គតចិត្ត ២៧, លោកុត្តរចិត្ត ៨ ឬ ៤០ ។

❖ **អនិយយោគីចេតសិក** សំដៅសេចក្ដីថា ចេតសិក ដែលប្រកបមិនប្រាកដ មាន ១១ គឺ ឥស្សា, មច្ឆរិយ, កុក្កុច្ច, សម្មាវាចា, សម្មាកម្មន្ត, សម្មាអាជីវ, ករុណា, មុទិតា, មាន, ថីន, មិទ្ធ ។

❖ **នានាកទាចិចេតសិក** សំដៅសេចក្ដីថា ចេតសិក ដែលប្រកបបានមួយដងមួយកាល និង

មិនប្រកបព្រមគ្នា មាន ៨ គឺ ឥស្សា, មច្ឆរិយ, កុក្កុច្ច, សម្មាវាចា, សម្មាកម្ម, សម្មាអាជីវ, ករុណា, មុទិតា ។

❖ **កទាចិចេតសិក** សំដៅសេចក្ដីថា ចេតសិកដែលប្រកបបានមួយដងមួយកាល មាន១ គឺ ១។

❖ **សហកទាចិចេតសិក** សំដៅសេចក្ដីថា ចេតសិក ដែលប្រកបបានមួយដងមួយកាលតែព្រមគ្នា មាន ២ គឺ ថីន, មិទ្ធ ។

❖ **និយតយោគីចេតសិក** សំដៅសេចក្ដីថា ចេតសិក ដែលប្រកបបានប្រាកដ មាន ៤១ គឺ

ចេតសិក ៤១, ដែលក្រៅអំពីនិយតយោគីចេតសិក ១១ ។

## សង្គហន័យដោយពិស្ដារចែកចេតសិក ២៧ ដោយអកុសលចេតសិក ១២

**១.លោភមូលចិត្តទី ១** មានចេតសិកប្រកប ១៩ គឺ អញ្ញសមានចេតសិ ១៣, មោចតុក ៤, លោភ, ទិដ្ឋិ ។

**២.លោភមូលចិត្តទី ២** មានចេតសិក ២១ គឺ អញ្ញសមានចេតសិក ១៣, មោចតុក ៤, លោភ, មាន, ថីទុក ២ ។

**៣.លោភមូលចិត្តទី ៣** មានចេតសិកប្រកប ១៩ គឺ អញ្ញសមានាចេតសិក ១៣, មោចតុក ៤, លោភ, មាន, ។

**៤.លោភមូលចិត្តទី ៤** មានចេតសិកប្រកប ២១ គឺ អញ្ញសមានាចេតសិក ១៣, មោចតុក ៤, លោភ, មាន, ថីទុក ២ ។

**៥.លោភមូលចិត្តទី ៥** មានចេតសិកប្រកប ១៨, គឺ អញ្ញសមានាចេតសិក ១២ (វៀរបីតិ), មោចតុក ៤, លោភ, ទិដ្ឋិ ។

**៦.លោភមូលចិត្តទី ៦** មានចេតសិកប្រកប ២០ គឺ អញ្ញសមានាចេតសិក ១២ (វៀរបីតិ), មោចតុក ៤, លោភ, ទិដ្ឋិ, ថីទុក ២ ។

**៧.លោភមូលចិត្តទី ៧** មានចេតសិកប្រកប ១៨ គឺ អញ្ញសមានាចេតសិក ១២ (វៀរបីតិ), មោចតុក ៤, លោភ, មាន ។

**៨.លោភមូលចិត្តទី ៨** មានចេតសិកប្រកប ២០ គឺ អញ្ញសមានាចេតសិក ១២ (វៀរបីតិ), មោចតុក ៤, លោភ, មាន, ថីទុក ២ ។

**៩.ទោសមូលចិត្តទី ១** មានចេតសិកប្រកប ២០ គឺ អញ្ញសមានាចេតសិក ១២ (វៀរបីតិ), មោចតុក ៤, ទោចតុក ៤ ។

**១០ទោសមូលចិត្តទី ២** មានចេតសិកប្រកប ២២ គឺ អញ្ញសមានាចេតសិក ១២ (វៀរបីតិ), មោចតុក ៤, ទោចតុក ៤, ថីទុក ២ ។

**១១.មោហមូលចិត្តទី ១** មានចេតសិកប្រកប ១៥ អញ្ញសមានាចេតសិក ១០ (វៀរអធិមោក្ខ, បីតិ, ឆន្ទ), មោចតុក ៤, វិចិកិច្ឆា ១ ។

**១២.មោហមូលចិត្តទី ២** មានចេតសិកប្រកប ១៥ គឺ អញ្ញសមានាចេតសិក ១១ (វៀរបីតិ, ឆន្ទ), មោចតុក ៤ ។

- **ទ្វិបញ្ចវិញ្ញាណចិត្ត ១០** មានចេតសិកប្រកប ៧ គឺ សព្វចិត្តសាធារណចេតសិក ៧ ។
- **សម្បដិច្ឆន្នចិត្ត ២, ឧបេក្ខាសន្តីរណចិត្ត ២, បញ្ចទ្វារាវជ្ជនចិត្ត ១** រួមជា ៥ មានចេតសិកប្រកប ១០ គឺ អញ្ញសមានាចេតសិក ១០ (វៀរវីរិយ, បីតិ, ឆន្ទ) ។
- **សោមនស្សន្តីរណចិត្ត** មានចេតសិកប្រកប ១១ គឺ អញ្ញសមានាចេតសិក ១១ (វៀរវីរិយ, ឆន្ទ) ។
- **មនោទ្វារាវជ្ជនចិត្ត** មានចេតសិកប្រកប ១១ គឺ អញ្ញសមានាចេតសិក ១១ (វៀរបីតី, ឆន្ទ) ។

❖ **ហសិតុប្បាទចិត្ត** មានចេតសិកប្រកប ១២ គឺ អញ្ញសមានាចេតសិក ១២ (វៀរឆន្ទ)។

**ចែកចេតសិក ៣៨ ដោយកាមាវចរសោភណចិត្ត ២៤**

▪ **មហាកុសលចិត្តទី ១ ទី ២** មានចេតសិកប្រកប ៣៨ គឺ អញ្ញសមានាចេតសិក ១៣, សោភណចេតសិក ២៥ ។

▪ **មហាកុសលចិត្តទី ៣ ទី ៤** មានចេតសិកប្រកប ៣៧ គឺ អញ្ញសមានាចេតសិក ១៣, សោភណចេតសិក ២៤ (វៀរបញ្ញា) ។

▪ **មហាកុសលចិត្តទី ៥ ទី ៦** មានចេតសិកប្រកប ៣៧ គឺ អញ្ញសមានាចេតសិក ១២ (វៀរបីតិ), សោភណចេតសិក ២៥ ។

▪ **មហាកុសលចិត្តទី ៧ ទី ៨** មានចេតសិកប្រកប ៣៦ គឺ អញ្ញសមានាចេតសិក ១២ (វៀរបីតិ), សោភណចេតសិក ២៤ (វៀរបញ្ញា) ។

➢ **មហាវិបាកចិត្តទី ១ ទី ២** មានចេតសិកប្រកប ៣៣ គឺ អញ្ញសមានាចេតសិក ១៣, សោភណសាធារណចេតសិក ១៩, បញ្ញា ១ ។

➢ **មហាវិបាកចិត្តទី ៣ ទី ៤** មានចេតសិកប្រកប ៣២ គឺ អញ្ញសមានាចេតសិក ១៣, សោភណសាធារណចេតសិក ១៩ ។

➢ **មហាវិបាកចិត្តទី ៥ ទី ៦** មានចេតសិកប្រកប ៣២ គឺ អញ្ញសមានាចេតសិក ១២ (វៀរបីតិ), សោភណសាធារណចេតសិក ១៩, បញ្ញា ១ ។

➢ **មហាវិបាកចិត្ត ទី ៧ ទី ៨** មានចេតសិកប្រកប ៣១ គឺ អញ្ញសមានាចេតសិក ១២

(វៀរបីតិ), សោភណសាធារណចេតសិក ១៩ ។

➢ **មហាកិរិយាចិត្តទី ១ ទី ២** មានចេតសិកប្រកប ៣៥ គឺ អញ្ញសមានាចេតសិក ១៣, សោភណសាធារណចេតសិក ២២ (វៀរវិរិយ ៣) ។

➢ **មហាកិរិយាចិត្តទី ៣ ទី ៤** មានចេតសិកប្រកប ៣៤ គឺ អញ្ញសមានាចេតសិក ១៣, សោភណសាធារណចេតសិក ២២ (វៀរវិរតិ ៣, បញ្ញា ១) ។

➢ **មហាកិរិយាចិត្តទី ៥ ទី ៦** មានចេតសិកប្រកប ៣៤ គឺ អញ្ញសមានាចេតសិក ១២ (វៀរបីតិ), សោភណសាធារណចេតសិក ២១ (វៀរវិរតិ ៣, បញ្ញា ១) ។

➢ **មហាកិរិយាចិត្តទី ៧ ទី ៨** មានចេតសិកប្រកប ៣៣ គឺ អញ្ញសមានាចេតសិក ១២ (វៀរបីតិ), សោភណសាធារណចេតសិក ២១ (វៀរវិរតិ ៣, បញ្ញា ១) ។

## ចែកចេតសិក ៣៥ ដោយមហគ្គតចិត្ត ២៧

❖ **បឋមជ្ឈានចិត្ត ៣** មានចេតសិកប្រកប ៣៥ គឺ អញ្ញសមានាចេតសិក ១៣, សោភណ-សាធារណចេតសិក ២២ (វៀរវិរតិ ១) ។

❖ **ទុតិយជ្ឈានចិត្ត ៣** មានចេតសិកប្រកប ៣៤ គឺ អញ្ញសមានាចេតសិក ១២ (វៀរវិតក្ក), សោភណសាធារណចេតសិក ២២ (វៀរវិរតិ ៣) ។

❖ **តតិយជ្ឈានចិត្ត ៣** មានចេតសិកប្រកប ៣៣ គឺ អញ្ញសមានាចេតសិក ១១ (វិតក្ក, វិចារ), សោភណសាធារណចេតសិក ២២ (វៀរវិរតិ ៣) ។

❖ **ចតុត្ថជ្ឈានចិត្ត ៣** មានចេតសិកប្រកប ៣២ គឺ អញ្ញសមានាចេតសិក ១០ (វៀរវិតក្ក, វិចារ, បីតិ), សោភណសាធារណចេតសិក ២២ (វៀរវិរតិ ៣) ។

❖ **បញ្ចមជ្ឈានចិត្ត ១៥** មានចេតសិកប្រកប ៣០ គឺ អញ្ញសមានាចេតសិក ១០ (វៀរវិតក្ក,

វិចារ, បីតិ), សោភណសាធារណចេតសិក ២០ (វៀរវិរតិ ៣, អប្បមញ្ញា ២) ។

## ចែកចេតសិក ៣៦ ដោយលោកុត្តរចិត្ត ៤០

❖ **បឋមជ្ឈានចិត្ត ៨** មានចេតសិកប្រកប ២៦ គឺ អញ្ញសមានាចេតសិក ១៣, សោភណ-សាធារណចេតសិក ២៣ (វៀរអប្បមញ្ញា ២) ។

❖ **ទុតិយជ្ឈានចិត្ត ៨** មានចេតសិកប្រកប ៣៥ គឺ អប្បមញ្ញាចេតសិក ១២ (វៀរវិតក្ក), សោភណសាធារណចេតសិក ២៣ (វៀរអប្បមញ្ញា ២) ។

❖ **តតិយជ្ឈានចិត្ត ៨** មានចេតសិកប្រកប ៣៤ គឺ អញ្ញសមានាចេតសិក ១១ (វៀរវិតក្ក, វិចារ), សោភណសាធារណចេតសិក ២៣ (វៀរអប្បមញ្ញា ២) ។

❖ **ចតុត្ថជ្ឈានចិត្ត ៨** និង បញ្ចមជ្ឈានចិត្ត ៨ មានចេតសិកប្រកប ៣៣ គឺ អញ្ញសមានា-ចេតសិក ១០(វៀរអប្បមញ្ញា ២ ) ។

(ចប់ចេតសិកបរមត្ថ)

## រូបបរមត្ថ ២៨

*ក-សភាវរូប ១៨ គឺ:*

**បឋវីធាតុ** (ធាតុដី), **អាបោធាតុ** (ធាតុទឹក), **តេជោធាតុ** (ធាតុភ្លើង), **វាយោធាតុ** (ធាតុខ្យល់), **ចក្ខុបសាទរូប** (ភ្នែក), **សោតបសាទរូប** (ត្រចៀក), **ឃានបសាទរូប** (ច្រមុះ), **ជិវ្ហាបសាទរូប** (អណ្តាត), **កាយបសាទរូប** (កាយ), **រូបារម្មណ** (រូប), **សទ្ទារម្មណ៍** (សម្លេង), **គន្ធារម្មណ៍** (ក្លិន), **រសារម្មណ៍** (រស), **ឥត្ថីភាវរូប** (រូបស្រី), **បុរិសភាវរូប** (រូបប្រុស), **ហទយវត្ថុរូប** (បេះដូង), **ជីវិតរូប** (ជីវិត), **អាហាររូប** (អាហារ) ។

*ខ-អសភាវរូប ១០ គឺៈ*

**បរិច្ឆេទរូប** (រូបជាចន្លោះ), **កាយវិញ្ញត្តិរូប** (កំរើកកាយ, **វចីវិញ្ញត្តិរូប** (កំរើកវាចា), **រូបលហុតា** (រូបស្រាល), **រូបមុទុតា** (រូបទន់), **រូបកម្មញ្ញតា** (រូបគួរដល់ការងារ), **ឧចយរូប** (រូបកើតឡើង), **សន្តតិរូប** (តំណនៃរូប), **ជរតារូប** (រូបជរា), **អនិច្ចតារូប** (រូបមិនទៀង) ។

-**មហាភូតរូប** ៤ គឺៈ បឋវី, អាបោ, តេជោ, វាយោ ។

-**ឧបាទាយរូប** ២៤ គឺៈ បសាទរូប ៥, វិសយរូប ៤ ឬ ៧, ហទយរូប ១, ឥត្ថីភាវរូប ១, បុរិសភាវរូប ១,អាហាររូប ១, ជីវិតរូប ១, វិញ្ញត្តិរូប ១, អាកាសរូប (បរិច្ឆេទរូប), វិការរូប ៣, លក្ខណរូប ៤ ។

-**រូប** ៩ កើតតែអំពីកម្មសុទ្ធ គឺៈ បសាទរូប ៥, ភាវរូប ២, ជីវិតរូប ១, ហទយរូប ១ ។

-**រូប** ២ កើតតែអំពីចិត្តសុទ្ធ គឺៈ កាយវិញ្ញត្តិរូប ១, វចីវិញ្ញត្តិរូប ១ ។

-**រូប** ១ គឺ សំឡេង កើតអំពីចិត្តក៏មាន កើតអំពីឧតុក៏មាន ។

-**វិការរូប** ៣ គឺៈ រូបលហុតា, រូបមុទុតា, រូបកម្មញ្ញតា ។ វិការរូប ៣ នេះ កើតអំពីចិត្តក៏មាន កើតអំពីអាហារក៏មាន ។

-**រូប** ៩ គឺៈ មហាភូតរូប ៤, និង វណ្ណោ ១, គន្ធោ ១, រសោ ១, ឱជា ១, អាកាសធាតុ ១ ។ រូប ៩ នេះ កើតអំពីកម្មក៏មាន កើតអំពីចិត្តក៏មាន កើតអំពីឧតុក៏មាន កើតអំពីអាហារក៏មាន ។

## អាការៈ ៣២ ចែកជាធាតុ ៤

## ១.ធាតុដី មាន ២០ និងចែកជា ៤ ពួក គឺ:

## ១.ធាតុដី ២០

1-**តចបញ្ចកៈ** កេសា (សក់), លោមា (រោម), នខា (ក្រចក), ទន្តា (ធ្មេញ), តចោ (ស្បែក) ។

2-**វក្កបញ្ចកៈ** មំសំ (សាច់), នហារូ (សសៃ), អដ្ឋិ (ឆ្អឹង), អដ្ឋិមិញ្ជំ (ខួរក្នុងឆ្អឹង), វក្កំ (ទាច) ។

3-**បប្ផាសបញ្ចកៈ** ហទយំ (បេះដូង), យកនំ (ថ្លើម), កិលោមកំ (វាវ), បិហកំ (ក្រពះ), បប្ផាសំ (សួត) ។

4-**អន្តំ** (ពោះវៀនធំ), អន្តគុណំ (ពោះវៀនតូច), ឧទរយំ (អាហារថ្មី), ករីសំ (អាហារចាស់), មត្ថលុង្គំ (ខួរក្នុងក្បាល) ។

## ២.ធាតុទឹក មាន ១២ ចែកជា ២ ពួក

1-**ពួកមេទឆក្កៈ** បិត្តំ (ប្រមាត់), សេម្ហំ (ស្លេស្ម), បុព្វោ (ខ្ទុះ), លោហិតំ (ឈាម), សេទោ (ញើស), មេទោ (ខ្លាញ់ខាប់) ។

2-**ពួកមុត្តឆក្កៈ** អស្សុ (ទឹកភ្នែក), វសា (ខ្លាញ់រាវ), ខេឡោ (ទឹកមាត់), សង្ឃានិកា (ទឹកសំបោ), លសិកា (ទឹករំអិល), មុត្តំ (ទឹកមូត្រ) ។

## ៣.ធាតុភ្លើង មាន ៤

**១.ឧស្មាតេជោ** ភ្លើងដែលធ្វើឲ្យរាកាយក្តៅ ។

**២.បាចកតេជោ** ភ្លើងរំលាយអាហារ ។

**៣.ជីរណតេជោ** ភ្លើងដែលធ្វើឲ្យទ្រុឌទ្រោម មានធ្មេញចាក់ សក់ស្កូវ ជាដើម ។

**៤.សន្តាបនតេជោ** ភ្លើងដែលធ្វើឲ្យក្តៅ រហូតដល់មានជម្ងឺ ។

## ៤.ធាតុខ្យល់ មាន ៦

**១.ឧទ្ធង្គមវាយោ** ខ្យល់ដែលបក់ឡើងទៅខាងលើ ។

**២.អធោគមវាយោ** ខ្យល់ដែលបក់ចុះក្រោម ។

**៣.កុច្ឆិសយវាយោ** ខ្យល់ក្នុងផ្ទៃពោះ ។

**៤.កោដ្ឋាសយវាយោ** ខ្យល់ក្នុងពោះវៀន ។

**៥.អង្គមង្គានុសារិវាយោ** ខ្យល់ត្រាច់ទៅតាមអវយវៈតូចធំ ។

**៦.អស្សាសបស្សាសវាយោ** ខ្យល់ដកដង្ហើមចូល-ចេញ ។

## អានិសង្សរបស់កម្មដ្ឋាន

១.កម្មដ្ឋាន ១០ គឺ ពុទ្ធានុស្សតិ, ធម្មានុស្សតិ, សង្ឃានុស្សតិ, សីលានុស្សតិ, ចាគានុស្សតិ, ទេវតានុស្សតិ, ឧបសមានុស្សតិ, មរណានុស្សតិ ត្រូវជា ៨ និង បដិកូលសញ្ញា ១ ធាតុវវដ្ឋាន មានត្រឹមតែ ឧបចារៈ ។

២.កម្មដ្ឋានដែលនៅសល់ ៣០ គឺ កសិណ ១០, អសុភ ១០, អានាបានស្សតិ ១, កាយគតាសតិ ១, ព្រហ្មវិហារ ៤, អរូប ៤ នេះមានទាំង ឧបចារៈ និង អប្បនាភាវនា ។

៣.កសិណ ១០, អានាបានស្សតិ ១ ទាំង ១ នេះ ឲ្យសម្រេច រូបឈាន តាំងអំពី បឋមជ្ឈានដល់ បញ្ចមជ្ឈាន ។

៤.អសុភ ១០, កាយគតាសតិ ១ ទាំង ១១ នេះ ឲ្យសម្រេចបានត្រឹមតែ បឋមជ្ឈាន ។

៥.ព្រហ្មវិហារ ៣ គឺ មេត្តា ១, ករុណា ១, មុទិតា ១ ឲ្យសម្រេចបានត្រឹមតែ ចតុត្ថជ្ឈាន ។

៦.ឧបេក្ខាព្រហ្មវិហារ ឲ្យសម្រេចបានត្រឹមតែ បញ្ចមជ្ឈាន ។

## សង្គ្រោះចរិត ៦ ក្នុងកម្មដ្ឋាន ៤០

**១.អសុភ ១០**, **កាយគតាសតិ ១** ជាទីសប្បាយនៃបុគ្គល រាគចរិត ។

**២.អប្បមញ្ញា ៤**, **វណ្ណកសិណ ៤** ជាទីសប្បាយនៃបុគ្គល ទោសចរិត ។

**៣.អានាបានស្សតិ ១** ជាទីសប្បាយនៃបុគ្គល មោហចរិត ។

**៤.ពុទ្ធានុស្សតិ**, **ធម្មានុស្សតិ**, **សង្ឃានុស្សតិ**, **សីលានុស្សតិ**, **ចាគានុស្សតិ**, **ទេវតានុស្សតិ** ជាទីសប្បាយនៃបុគ្គល សទ្ធាចរិត ។

**៥.ឧបសមានុស្សតិ ១, សរណានុស្សតិ ១, បដិកូលសញ្ញា ១, ធាតុវវដ្ឋាន ១** ជាទីសប្បាយនៃបុគ្គល ពុទ្ធិចរិត ។

## អាការៈទាំង ១០ យ៉ាង របស់កម្មដ្ឋាន

**១.សង្ខាតនិទ្ទេស** ត្រូវដឹងអាការៈ ដែលលោកសំដែងចេញរាប់ចំនួន ។

**២.ឧបចារប្បនាវហា** ត្រូវដឹងកម្មដ្ឋាន ដែលនាំនូវ ឧបចារជ្ឈាន និងកម្មដ្ឋាន ដែលនាំមកនូវ អប្បនាឈាន ។

**៣.ឈានប្បភេទ** ត្រូវដឹងប្រភេទរបស់ឈាន ។

**៤.សមតិក្កម** ត្រូវដឹងវិធីកន្លងរបស់កម្មដ្ឋាន ។

**៥.វឌ្ឍនាវឌ្ឍន** ត្រូវដឹងកម្មដ្ឋាន ដែលគួរចំរើនថែម និងមិនគួរចំរើនថែម ។

**៦.អារម្មណ** ត្រូវអារម្មណ៍របស់កម្មដ្ឋាន ។

**៧.ភូមិ** ត្រូវដឹងភូមិរបស់កម្មដ្ឋាន ។

**៨.គហណា** ត្រូវដឹងកិច្ចរៀនយកនូវកម្មដ្ឋាន ។

**៩.បច្ចយ** ត្រូវដឹងបច្ច័យរបស់កម្មដ្ឋាន ។

**១០.ចរិយានុកូល** ត្រូវដឹងកម្មដ្ឋានដែលសមគួរដល់ចរិត ។

## កម្មដ្ឋាន ៤០

## កសិណ ១០

**១.បឋវីកសិណ** យកដីធ្វើជាវង់កសិណ ។

**២.អាបោកសិណ** យកទឹកធ្វើជាវង់កសិណ ។

**៣.តេជោកសិណ** យកភ្លើងធ្វើជាវង់កសិណ ។

**៤.វាយោកសិណ** យកខ្យល់ធ្វើជាកសិណ ។

**៥.នីលកកសិណ** យកវត្ថុពណ៌ខៀវជាកសិណ ។

**៦.បីតកសិណ** យកវត្ថុមានពណ៌លឿងជាកសិណ ។

**៧.លោហិតកកសិណ** យកវត្ថុមានពណ៌ក្រហមជាកសិណ ។

**៨.ឱទាតកសិណ** យកវត្ថុមានពណ៌សជាកសិណ ។

**៩.អាកាសកសិណ** យកអាកាសដែលកំណត់ទុកជាកសិណ ។

**១០.អាលោកកសិណ** យកពន្លឺជាកសិណ ។

## អសុភ ១០

**១.ឧទ្ធុមាតក** អសុភហើមពោងពងឡើង ។

**២.វិនីលក** អសុភហើមមានពណ៌ខៀវ ដោយច្រើន ។

**៣.វិបុព្វក** អសុភហើមមានខ្ទុះហូរទៅ ក្នុងខាងលើ ខាងក្រោម ។

**៤.វិច្ឆិទ្ទក** អសុភដែលគេកាត់ដាច់ពាក់កណ្ដាលខ្លួន ។

**៥.វិក្ខាយិតក** អសុភដែលសត្វខាំកកេរសីU មានសំណាម រលុះរលួយផ្សេងៗ ។

**៦.វិក្ខិត្តក** អសុភដែលគេកាត់ដាច់ចេញពីគ្នា ជាកំណាត់ៗ រាត់រាយទៅផ្សេងៗ ។

**៧.ហតវិក្ខិត្តក** អសុភដែលគេកាប់សាប់ មានស្នាមសាំរវាម ។

**៨.លោហិតក** អសុភត្រូវប្រហារ មានឈាមហូរស្រោចស្រព ។

**៩.បុឡុវក** អសុភមានដង្កូវចោះហូរចេញ តាមទ្វារទាំង ៩ ។

**១០.អដ្ឋិក** អសុភមានរាងឆ្អឹង រាត់រាយខ្ចាត់ខ្ចាយ ទៅផ្សេងៗ ។

### អនុស្សតិ ១០

**១.ពុទ្ធានុស្សតិ** សេចក្តីរលឹករឿយៗ មានពុទ្ធគុណ ជាអារម្មណ៍ ។

**២.ធម្មានុស្សតិ** សេចក្តីរលឹករឿយៗ មានធម្មគុណ ជាអារម្មណ៍ ។

**៣.សង្ឃានុស្សតិ** សេចក្តីរលឹករឿយៗ មានសង្ឃគុណ ជាអារម្មណ៍ ។

**៤.សីលានុស្សតិ** សេចក្តីរលឹករឿយៗ មានសីលគុណ ជាអារម្មណ៍ ។

**៥.ចាគានុស្សតិ** សេចក្តីរលឹករឿយៗ មានចាគគុណ ជាអារម្មណ៍ ។

**៦.ទេវតានុស្សតិ** សេចក្តីរលឹករឿយៗ មានសទ្ធាទិគុណ របស់ទេវតា និងសទ្ធាទិគុណរបស់ខ្លួនជាអារម្មណ៍ ។

**៧.មរណានុស្សតិ** សេចក្តីរលឹករឿយៗ នូវសេចក្តីស្លាប់ ជាអារម្មណ៍ ។

**៨.កាយគតានុស្សតិ** សេចក្តីរលឹកតាំងចុះក្នុងកាយ មានកោដ្ឋាសនិមិត្ត នៃអាការៈមានសក់ជាដើម។

**៩.អានាបានស្សតិ** សេចក្តីរលឹក មានអស្សាសបស្សាសនិមិត្ត ជាអារម្មណ៍ ។

**១០.ឧបសមានុស្សតិ** សេចក្តីរលឹករឿយៗ មានគុណរបស់ព្រះនិព្វាន ដែលជាទីរម្ងាប់នូវទុក្ខ

ទាំងពួងជាអារម្មណ៍ ។

## ព្រហ្មវិហារ ៤

**១.មេត្តា** ផ្សាយមេត្តា ដល់សព្វសត្វទាំងអស់ ។

**២.ករុណា** ផ្សាយករុណា ដល់សព្វសត្វទាំងអស់ ។

**៣.មុទិតា** ផ្សាយមុទិតា ដល់សព្វសត្វទាំងអស់ ។

**៤.ឧបេក្ខា** ផ្សាយឧបេក្ខា ដល់សព្វសត្វទាំងអស់ ។

## អារុប្ប ៤

**១.អាកាសានញ្ចាយតន** យកអាកាសក្នុងបដិភាគនិមិត្ត អំពីកសិណ ៩ លើកអាកាសកសិណចេញដែលមិនមានទីបំផុត ជាអារម្មណ៍ ។

**២.វិញ្ញាណញ្ចាយតន** ស្រាវយកអរូបវិញ្ញាណទី ១ ដែលផ្សាយទៅ ដែលមិនមានទីបំផុតមកជាអារម្មណ៍ ។

**៣.អាកិញ្ចញ្ញាយតន** កំណត់យកអរូបវិញ្ញាណទី ២ ដែលផ្សាយទៅ មិនមានកង្វល់តិចតួចមកជាអារម្មណ៍ ។

**៤.នេវសញ្ញានាសញ្ញាយតន** កំណត់យកសេចក្ដីល្អិត របស់អរូបវិញ្ញាណទី ៣ ដែលមានស្មើរតែនឹងមិនមាន មកជាអារម្មណ៍ ។

-**អាហារេបដិកូលសញ្ញា ១** ដែលយោគាវចរពិចារណា អាហារដោយបដិកូល ។

-**ចតុធាតុវវដ្ឋាន ១** ដែលព្រះយោគាវចរពិចារណា កំណត់ធាតុទាំង ៤ ក្នុងករជកាយ ។

## ពោធិបក្ខយធម៌ (ធម៌ជាគ្រឿងត្រាស់ដឹង) ៣៧ ប្រការ

១.សតិប្បដ្ឋាន ៤ គឺៈ

1-**កាយានុបស្សនាសតិប្បដ្ឋាន** ពិចារណាឃើញកាយ ក្នុងកាយ ។

2-**វេទនានុបស្សនាសតិប្បដ្ឋាន** ពិចារណាឃើញវេទនា ក្នុងវេទនា ។

3-**ចិត្តានុបស្សនាសតិប្បដ្ឋាន** ពិចារណាឃើញចិត្ត ក្នុងចិត្ត ។

4-**ធម្មានុបស្សនាសតិប្បដ្ឋាន** ពិចារណាឃើញធម៌ ក្នុងធម៌ ។

២.សម្មប្បធាន ៤ គឺៈ

1-**បហានប្បធាន** ព្យាយាមលះបាបអកុសលធម៌ ដែលកើតឡើងហើយ ។

2-**សំវរប្បធាន** ព្យាយាមញុំាងបាបអកុសល ដែលមិនទាន់កើត មិនឲ្យកើតឡើងបាន ។

3-**ភាវនាបធាន** ព្យាយាមញុំាងកុសល ដែលមិនទាន់កើត ឲ្យកើតឡើង ។

4-**អនុរក្ខនាបធាន** ព្យាយាមរក្សាកុសលធម៌ ដែលកើតឡើងហើយ ឲ្យរឹងរឹតតែចម្រើនឡើង ។

៣.ឥទ្ធិបាទ ៤ គឺៈ

1-**ឆន្ទិទ្ធិបាទ** មានឆន្ទៈ ។

2-**ចិត្តិទ្ធិបាទ** យកចិត្តទុកដាក់ ។

3-**វីរិយិទ្ធិបាទ** មានព្យាយាម ។

4-**វិមំសិទ្ធិបាទ** ពិចារណា ។

៤.ឥន្ទ្រិយ ៥ គឺ:

1-**សទ្ធិន្ទ្រិយ** មានសទ្ធា ។
2-**វីរិយិន្ទ្រិយ** ព្យាយាម ។
3-**សតិន្ទ្រិយ** មានសតិ ។
4-**សមាធិន្ទ្រិយ** មានសមាធិ ។
5-**បញ្ញិន្ទ្រិយ** មានបញ្ញា ។

៥.ពលៈ ៥ គឺ:

1-**សទ្ធាពល** កំលាំងសទ្ធា ។
2-**វីរិយពល** កំលាំព្យាយាម ។
3-**សតិពល** កំលាំងសតិ ។
4-**សមាធិពល** កំលាំងសមាធិ ។
5-**បញ្ញាពល** កំលាំងបញ្ញា ។

៦.ពោជ្ឈង្គ ៧ គឺ:

1-**សតិសម្ពោជ្ឈង្គ** គ្រឿងត្រាស់ដឹង គឺសតិ ។
2-**ធម្មវិចយសម្ពោជ្ឈង្គ** គ្រឿងត្រាស់ដឹង គឺពិចារណាធម៌ ។
3-**វីរិយសម្ពោជ្ឈង្គ** គ្រឿងត្រាស់ដឹង គឺព្យាយាម ។
4-**បីតិសម្ពោជ្ឈង្គ** គ្រឿងត្រាស់ដឹង គឺបីតិ ។
5-**បស្សទ្ធិសម្ពោជ្ឈង្គ** គ្រឿងត្រាស់ដឹង គឺបស្សទ្ធិ ។
6-**សមាធិសម្ពោជ្ឈង្គ** គ្រឿងត្រាស់ដឹង គឺសមាធិ ។
7-**ឧបេក្ខាសម្ពោជ្ឈង្គ** គ្រឿងត្រាស់ដឹង គឺឧបេក្ខា ។

៧.អរិយមគ្គអង្គ ៨ គឺ:

1-**សម្មាទិដ្ឋិ** ការយល់ឃើញត្រូវ ។
2-**សម្មាសង្កប្បោ** សេចក្តីត្រិះរិះត្រូវ ។
5-**សម្មាអាជីវោ** កិរិយាចិញ្ចឹមជីវិតត្រូវ ។
6-**សម្មាវាយាមោ** ព្យាយាមត្រូវ ។

3-**សម្មាវាចា** សំដីត្រូវ ។ 7-**សម្មាសតិ** សេចក្តីរលឹកត្រូវ ។

4-**សម្មាកម្មន្តោ** ការងារត្រូវ ។ 8-**សម្មាសមាធិ** កិរិយាតម្កល់ចិត្តហ្នឹងត្រូវ ។

5-**សម្មាអាជីវោ** កិរិយាចិញ្ចឹមជីវិតត្រូវ ។ រួមត្រូវជា ពោធិបក្ខិយធម៌ មាន ៣៧ ប្រការ ។

## ភូមិរបស់វបស្ស ៦ យ៉ាង

**១. ខន្ធ ៥ គឺ:** រូប, វេទនា, សញ្ញា, សង្ខារ, វិញ្ញាណ ។

**២.អាយតនៈ ១២ គឺ:** ភ្នែក, ត្រចៀក, ច្រមុះ, អណ្តាត, កាយ, ចិត្ត, (នេះជាអាយតនៈខាងក្នុង៦), រូប, សំឡេង, ក្លិន, រស, ផោដ្ឋព្វៈ, ធម្មារម្មណ៍ (នេះជាអាយតនៈខាងក្រៅ ៦) ។

**៣.ធាតុ ៤ គឺ:** បឋវីធាតុ, អាបោធាតុ, តេជោធាតុ, វាយោធាតុ ។

**៤.សច្ច ៤ គឺ:** ទុក្ខសច្ច, សមុទយសច្ច, និរោធសច្ច, មគ្គសច្ច ។

**៥.ឥន្ទ្រិយ ២២ គឺ:** ចក្ខុន្ទ្រិយ, សោតិន្ទ្រិយ, ឃានិន្ទ្រិយ, ជិវ្ហិន្ទ្រិយ, កាយិន្ទ្រិយ, មនិន្ទ្រិយ, ឥត្ថិន្ទ្រិយ, បុរិសិន្ទ្រិយ, ជីវិតិន្ទ្រិយ, សុខិន្ទ្រិយ, ទុក្ខិន្ទ្រិយ, សោមនស្សិន្ទ្រិយ, ទោមនស្សិន្ទ្រិយ, ឧបេក្ខិន្ទ្រិយ, សទ្ធិន្ទ្រិយ, វីរិយិន្ទ្រិយ, សតិន្ទ្រិយ, សមាធិន្ទ្រិយ, បញ្ញិន្ទ្រិយ, អនញ្ញតញ្ញស្សាមីតិន្ទ្រិយ, អញ្ញិន្ទ្រិយ, អញ្ញាតាវិន្ទ្រិយ ។

**៦.បដិច្ចសមុប្បាទ ១២ គឺ:**

1-**អវិជ្ជាបច្ចយា សង្ខារា** សង្ខារទាំងឡាយ (កើតមាន)ព្រោះបច្ច័យគឺអវិជ្ជាពោលគឺសេចក្តីល្ងង់។

2-**សង្ខារប្បច្ចយា វិញ្ញាណំ** វិញ្ញាណ (កើតមាន) ព្រោះបច្ច័យគឺសង្ខារ ។

3-**វិញ្ញាណប្បច្ចយា នាមរូបំ** នាមនិងរូប (កើតមាន) ព្រោះបច្ច័យគឺវិញ្ញាណ ។

4-**នាមរូបប្បច្ចយា សឡាយតនំ** អាយតនៈ ៦ (កើតមាន) ព្រោះបច្ច័យគឺនាមនិងរូប ។

5-**សឡាយតនប្បច្ចយា ផស្សោ** សម្ផស្ស (កើតមាន) ព្រោះបច្ច័យគឺអាយតនៈ ៦ ។

6-**ផស្សប្បច្ចយា វេទនា** វេទនា (កើតមាន) ព្រោះបច្ច័យគឺសម្ផស្ស ។

7-**វេទនាបច្ចយា តណ្ហា** តណ្ហា (កើតមាន) ព្រោះបច្ច័យគឺវេទនា ។

8-**តណ្ហាបច្ចយា ឧបាទានំ** ឧបាទាន (កើតមាន) ព្រោះបច្ច័យគឺតណ្ហា ។

9-**ឧបាទានប្បច្ចយា ភវោ** ភព (កើតមាន) ព្រោះបច្ច័យគឺឧបាទាន ។

10-**ភវប្បច្ចយា ជាតិ** ជាតិ (កើតមាន) ព្រោះបច្ច័យគឺភព ។

11-**ជាតិប្បច្ចយា ជរាមរណំ** ជរានិងមរណៈ (កើតមាន) ព្រោះបច្ច័យគឺជាតិ ។

12-**សោកបរិទេវទុក្ខទោមនស្សុបាយាសា សម្ភវន្តិ** សេចក្តីសោក សេចក្តីខ្សឹកខ្សួល សេចក្តីព្រួយ សេចក្តីតូចចិត្ត និងសេចក្តីចង្អៀតចង្អល់ចិត្តទាំង ក៏រមែងកើតមាន (ព្រោះជាតិជាបច្ច័យដែរ) ។

- ត្រូវចាំថាៈ បើបច្ច័យរលត់ ព្រោះរលត់បច្ច័យដែរ ។

## និព្វានបរមត្ថ ២ យ៉ាង គឺៈ

**១.សឧបាទិសេសនិព្វានធាតុ** រំលត់កិលេស តែខន្ធនៅសល់ នៅឡើយ ។

**២.អនុបាទិសេសនិព្វានធាតុ** រំលត់ទាំងកិលេស ទាំងខន្ធក៏បែកធ្លាយទៅ ។

## ទុក្ខសច្ច មានអត្ថ ៤ យ៉ាង

**១.បីឡនត្ថោ** ដោយអត្ថថា បៀតបៀនសត្វឲ្យលំបាក ។

**២.សំខតដ្ឋោ** ដោយអត្ថថា តណ្ហាជាបច្ច័យតាក់តែង ។

**៣.សន្តាបដ្ឋោ** ដោយអត្ថថា ញុាំងសត្វឲ្យក្តៅ ។

**៤.វិបរិណាមដ្ឋោ** ដោយអត្ថថា ធ្វើសត្វឲ្យប្រែប្រួល វិបរិតផ្សេងៗ ។

## សមុទយសច្ច មានអត្ថ ៤ យ៉ាង

**១.អាយុហនដ្ឋោ** មានអត្ថថា ប្រមូលកងទុក្ខ ។

**២.និទានដ្ឋោ** មានអត្ថថា ជាហេតុឲ្យកើតកងទុក្ខ ។

**៣.សំយោគដ្ឋោ** មានអត្ថថា ប្រកបសត្វទុកក្នុងសង្សារវដ្ត ។

**៤.បលិពោធដ្ឋោ** មានអត្ថថា កង្វល់ដោយវត្ថុកាម ។

## និរោធសច្ច មានអត្ថ ៤ យ៉ាង

**១.និស្សរណដ្ឋោ** មានអត្ថថា រលាស់ខ្លួនចេញចាកភព ។

**២.វិវេកដ្ឋោ** មានអត្ថថា មិនកង្វល់ដោយវត្ថុកាម និង កិលេសកាម ។

**៣.អសំខតដ្ឋោ** មានអត្ថថា គ្មានបច្ច័យប្រជុំតាក់តែង ។

**៤.អមតដ្ឋោ** មានអត្ថថា ជាអមតធម៌ គឺ ធម៌មិនចេះស្លាប់ ។

## មគ្គសច្ច មានអត្ថ ៤ យ៉ាង

**១.និយ្យានដ្ឋោ** មានអត្ថថា នាំខ្លួនចេញចាកភព ។

**២.ហេតុដ្ឋោ** មានអត្ថថា ជាហេតុនៃព្រះនិព្វាន ។

**៣.និទស្សនដ្ឋោ** មានអត្ថថា សម្តែងចេញ គឺ បានឃើញច្បាស់នូវព្រះនិព្វាន ។

**៤.អធិបតេយ្យដ្ឋោ** មានអត្ថថា ជាធំក្នុងការរម្ងាប់កងទុក្ខទាំងពួង ។

**បទរបស់ព្រះនិព្វាន ៩ បទ គឺៈ**

**១.រាគវិរាគាយ** ដើម្បីប្រាសចាកតម្រេក ។

**២.មទនិម្មទនាយ** ដើម្បីញ៉ាំញីនូវសេចក្តីស្រវឹង ។

**៣.បិបាសវិនយាយ** ដើម្បីកំចាត់បង់នូវការស្រេចឃ្លានក្នុងកាម ។

**៤.អាលយសមុគ្ឃាតាយ** ដើម្បីដកចេញនូវសេចក្តីអាល័យក្នុងកាម ។

**៥.វដ្តូបច្ឆេទាយ** ដើម្បីផ្តាច់បង់នូវវដ្តៈ ។

**៦.តណ្ហាក្ខយាយ** ដើម្បីអស់ទៅនៃតណ្ហា ។

**៧.វិរាគាយ** ដើម្បីមិនមានរាគៈ ។

**៨.និរោធាយ** ដើម្បីរំលត់បង់ ។

**៩.និព្វានាយ** ដើម្បីព្រះនិព្វាន ។

រៀបរៀងដោយ ព្រះភិក្ខុ **កោសល្លធម្ម នួន សារ៉េត** (ព្រះជន្ម ៣៥)

ថ្ងៃចន្ទ ៩រោច ខែកត្តិក ឆ្នាំវក អដ្ឋស័ក ព.ស.២៥៦០, គ.ស.២០១៦